ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ




# សៀវភៅរបាយការណ៍
# លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ

**ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងខេត្តព្រះវិហារ**

**រៀបចំដោយ៖**

នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

**រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០២០**

# មាតិកា

ទំព័រ


**បុព្វកថា** ........ iii.

**អារម្ភកថា** ........ iv.

**ជំពូក ១៖ សេចក្តីផ្តើម** ........ ១

១.១. សាវតា ........ ១

១.២. គោលបំណង ........ ២

១.៣. វិធីសាស្រ្តនៃការប្រមូលទិន្នន័យ ........ ២

១.៤. ការកែច្នៃទិន្នន័យ ........ ២

**ជំពូក ២៖ ការវិភាគទិន្នន័យ** ........ ៣

២.១. ព័ត៌មានប្រជាសាស្រ្ត ........ ៣

២.១. ព័ត៌មានប្រជាសាស្រ្ត ........ ៣

២.១.២. ព័ត៌មានពីប្រជាជន ........ ៥

២.១.៣. ប្រជាជនធ្វើការបំលាស់ប្តូរទីលំនៅ ........ ៧

២.១.៤. លំនៅដ្ឋាន ........ ១២

២.១.៤. សម្ភារៈបរិក្ខារដែលទាក់ទងការដឹកជញ្ជូន គ្រឿងម៉ាស៊ីន និងយានយន្ត ........ ១៧

២.២. អត្រាកំណើត និងមរណភាព ........ ២១

២.២.១. អត្រាកំណើត ........ ២១

២.២.២. មរណភាព ........ ២៣

២.៣. ប្រជាជនពិការ ........ ២៦

២.៣.១. ពិការភាពនៃបុគ្គល ........ ២៦

២.៤. ការប្រើប្រាស់ទឹក និង អនាម័យ ........ ៣០

២.៥. បរិស្ថាន និងធនធានធម្មជាតិ ........ ៣៣

២.៦. គ្រោះធម្មជាតិ ........ ៣៦

២.៧. សន្តិសុខសង្គម និងសេដ្ឋកិច្ច ........ ៣៧

២.៧.១. អសន្តិសុខសង្គម ........ ៣៧

២.៧.២. ស្ថានភាពសេដ្ឋកិច្ចគ្រួសារ ........ ៤៤

២.៧.៣. លំហូរនៃការវិនិយោគតាមប្រភេទនៃសកម្មភាពអភិវឌ្ឍន៍ ........ ៤៨

២.៨. វិស័យអប់រំ និងសេវាសង្គម ........ ៤៨

២.៨.១. ផ្នែកការសិក្សាអប់រំ ........ ៤៨

២.៨.១.១ ចំនួនគ្រឹះស្ថានសិក្សា ........ ៤៩

២.៨.១.២ ចម្ងាយពីភូមិទៅគ្រឹះស្ថានសិក្សា ........ ៥១

២.៨.២. ផ្នែកសេវាសង្គម ........ ៥៣

២.៩. ការស្ថាបនាផ្លូវគមនាគមន៍ ........ ៥៥

២.១០. ផ្នែកសុខាភិបាល ........ ៥៦

២.១០.១. សេវាកម្មសុខភាព ....................................................................................... ៥៦
២.១០.២. ប្រេវ៉ាឡង់ជំងឺសំខាន់ៗ ....................................................................................... ៥៨
២.១០.៣. គ្រួសារដែលមានជំងឺអេដស៍ឬផ្ទុកមេរោគអេដស៍ និងកុមារកំព្រា ........................................ ៦៣
២.១១. ផ្នែកកសិកម្ម ....................................................................................... ៦៥
២.១១.១. គ្រួសារកាន់កាប់តាមទំហំផ្ទៃដី ....................................................................................... ៦៥
២.១១.២. ផ្ទៃដីដែលបានដាំដុះ និងផ្ទៃដីប្រមូលផល ....................................................................................... ៦៧
២.១១.៣. ផ្ទៃដីដាំដំណាំដែលបានប្រើប្រាស់ប្រព័ន្ធស្រោចស្រព ....................................................................................... ៦៨
២.១១.៤. ការប្រើប្រាស់ធាតុចូលក្នុងកសិកម្ម ....................................................................................... ៦៩
២.១១.៥. ការចិញ្ចឹមបសុសត្វ និងបសុបក្សីរបស់គ្រួសារ ....................................................................................... ៧១
**ជំពូក ៣៖ សន្និដ្ឋាន និងអនុសាសន៍ ....................................................................................... ៧៦**
៣.១. សន្និដ្ឋាន ....................................................................................... ៧៦
៣.២. អនុសាសន៍ ....................................................................................... ៧៦
**ឯកសារភ្ជាប់៖ កម្រងសំណួរស្ថិតិថ្នាក់ក្រោមជាតិ ....................................................................................... ៧៧**

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយ នឹងបង្ហាញជូនរបាយការណ៍លទ្ធផលវិភាគ ស្តីពីស្ថិតិថ្នាក់ក្រោមជាតិជំហានទី៣ ដោយផ្អែកលើទិន្នន័យដែលបានប្រមូលចំនួន ៥ ខេត្ត គឺខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងខេត្តព្រះវិហារ ។ របាយការណ៍នេះបានប្រមូលនូវទិន្នន័យសំខាន់ៗរួមមានៈ ស្ថិតិប្រជាសាស្ត្រ ស្ថិតិកសិកម្ម ស្ថិតិសេដ្ឋកិច្ច និងស្ថិតិសង្គមកិច្ច សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការកសាងផែនការ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ស្របតាមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។

ខ្ញុំសូមថ្លែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅដល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានសម្រេចឱ្យក្រសួងផែនការបង្កើតនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នេះឡើងតាមអនុក្រឹត្យ លេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០១៤ កន្លងមក ។

សូមថ្លែងអំណរគុណដល់ ឯកឧត្តម **ហោ ដារិទ្ធ** រដ្ឋលេខាធិការ ក្រសួងផែនការ លោកជំទាវ **ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានដឹកនាំ និងសម្របសម្រួលការងារនេះតាំងពីចាប់ផ្តើម ដោយមានជំនួយការពីឯកឧត្តមបណ្ឌិត **ម៉េង គឹមហ៊ី** ឯកឧត្តម **ពេជ ពោធិ៍** អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ ទទួលបន្ទុកនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ឯកឧត្តម **ចាន់ សំអាត** ប្រធាននាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ លោក លោកស្រី អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ ព្រមទាំងមន្ត្រីទាំងអស់ដែលបានរួមចំណែកផលិតរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ។

សូមថ្លែងអំណរគុណដល់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត ឯកឧត្តម លោក លោកស្រី ប្រធានមន្ទីរផែនការខេត្ត និងសហការីនៃខេត្តទាំង៥ ដូចបានរៀបរាប់ខាងលើ ដែលបានជួយសហការយ៉ាងសកម្មនៅក្នុងអំឡុងពេលចុះស្រង់ទិន្នន័យជាក់ស្តែង។

ខ្ញុំសង្ឃឹមថា អ្នករៀបចំគោលនយោបាយ អ្នកធ្វើផែនការសម្រាប់អភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ អ្នកស្រាវជ្រាវ និងសាធារណៈជនទូទៅ នឹងប្រើប្រាស់របាយការណ៍ដ៏មានសារៈសំខាន់នេះ ៕

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

ភ្នំពេញ កម្ពុជា
ខែធ្នូ ឆ្នាំ២០២០

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

ការបោះពុម្ពផ្សាយសៀវភៅលើកទី៣ នៃរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ដែលបានផលិតឡើងដោយ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ដោយមានការសហការពីមន្ទីរផែនការខេត្តទាំង៥ ។ សៀវភៅនេះផ្តល់នូវទិន្នន័យសំខាន់ៗរួមមានៈស្ថិតិប្រជាសាស្ត្រ ស្ថិតិកសិកម្ម ស្ថិតិសេដ្ឋកិច្ច និង ស្ថិតិសង្គមកិច្ច ហើយទិន្នន័យនេះសម្រាប់យកមកបម្រើការកសាងផែនការ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ។

ការបោះពុម្ពផ្សាយសៀវភៅនេះមានតារាងជាតួលេខ និងក្រាហ្វិកដែលមានការវិភាគអធិប្បាយខ្លីៗ និងអាចប្រើប្រាស់ជាប្រភពទិន្នន័យ ព័ត៌មាន សម្រាប់អ្នកប្រើប្រាស់គ្រប់រូបដែលមានចំណាប់អារម្មណ៍ទៅលើទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ។ ទិន្នន័យនៅក្នុងសៀវភៅនេះត្រូវបានផលិតឡើងដំបូងបំផុតដោយ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សហការជាមួយមន្ទីរផែនការខេត្ត ជំហានទី១ បានចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិចំនួន ៥ ខេត្ត រួចមកហើយមាន៖ខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ ហើយជំហានទី២ បានចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិចំនួន ៤ ខេត្ត ដែលស្ថិតនៅតំបន់ឆ្នេរសមុទ្រមាន៖ ខេត្តកែប កំពត កោះកុង និងខេត្តព្រះសីហនុ និងជំហានទី៣ នេះនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ក៏បានបន្តចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិចំនួន ៥ ខេត្តទៀតមាន៖ ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងខេត្តព្រះវិហារ ។

ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអំណរគុណចំពោះក្រុមការងារនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ និងមន្ទីរផែនការខេត្ត ដែលបានចូលរួមចំណែកយ៉ាងធំធេង ក្នុងការរៀបចំចងក្រងបោះពុម្ពនូវទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ដ៏មានសារៈសំខាន់ជាលើកទី៣នេះ ៕

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ហាន់ លីណា**

ភ្នំពេញ កម្ពុជា
ខែធ្នូ ឆ្នាំ២០២០

# ជំពូក ១
# សេចក្តីផ្តើម

## ១.១ សាវតា

គម្រោងគាំទ្រស្ថិតិថ្នាក់ក្រោមជាតិ គឺជាគម្រោងមួយដែលវិទ្យាស្ថានជាតិស្ថិតិបានរៀបចំ ដើម្បីប្រមូលទិន្នន័យស្ថិតិថ្នាក់មូលដ្ឋាន និងធ្វើការវិភាគទៅលើលទ្ធផលទាំងនោះ ស្របតាមការធ្វើផែនការវិមជ្ឈការ និងវិសហមជ្ឈការសម្រាប់ថ្នាក់ក្រោមជាតិ ។

ស្ថិតិដែលត្រូវប្រមូលពីថ្នាក់មូលដ្ឋាន រួមមានស្ថិតិផ្នែកប្រជាសាស្ត្រ ស្ថិតិកសិកម្ម ស្ថិតិសេដ្ឋកិច្ច និង ស្ថិតិសង្គមកិច្ច ដែលត្រូវយកមកចងក្រងវិភាគ ។ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ជាអ្នកអនុវត្តគម្រោងនេះដោយផ្ទាល់ដែលស្របតាមភារកិច្ចរបស់នាយកដ្ឋាន និងតាមសេចក្តី សម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា** ស្នើឱ្យបង្កើតនាយកដ្ឋាននេះឡើងតាមអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ។

ប្រទេសកម្ពុជាបានបែងចែកជា ៤ តំបន់គឺ តំបន់វាលទំនាប តំបន់បឹងទន្លេសាប តំបន់ឆ្នេរសមុទ្រ និងតំបន់ភ្នំ និងខ្ពង់រាប។ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ក៏បានអនុវត្តចប់រួចរាល់បានចំនួន ២ជំហានរួចមកហើយ គឺជំហានទី១ បានអនុវត្តទៅលើខេត្តចំនួន ៥ មាន៖ បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងកំពង់ស្ពឺ និងជំហានទី២ ក៏បានអនុវត្តលើខេត្តចំនួន៤ ដែលនៅជាប់តំបន់ឆ្នេរសមុទ្រមាន៖ កំពត កោះកុង ព្រះសីហនុ និងកែប ចំពោះជំហានទី៣ នេះត្រូវបានអនុវត្តទៅលើខេត្តចំនួន៥ បន្តទៀតមាន៖ ក្រចេះ ស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី និងព្រះវិហារ សម្រាប់ឆ្នាំ២០១៨ ដែលជាខេត្តនៅក្នុងចំណោមរាជធានីខេត្តទាំង ២៥ របស់ប្រទេសកម្ពុជា ។



## ១.២ គោលបំណង

គោលបំណងសំខាន់ នៃគម្រោងស្ថិតិថ្នាក់ក្រោមជាតិ គឺធ្វើការវិភាគទិន្នន័យរកឱ្យឃើញនូវបញ្ហា ដែលអាចកើតមានឡើងនៅក្នុងមូលដ្ឋាន ដែលមានទិន្នន័យដែលទាក់ទងទៅព័ត៌មាន ផ្នែកប្រជាសាស្ត្រ ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកសុខាភិបាល អប់រំ និងផ្នែកកសិកម្ម របស់ខេត្តទាំង៥ ហើយទិន្នន័យ នេះក៏សម្រាប់យកមកបម្រើការកសាងផែនការ រៀបចំគោលនយោបាយ កម្មវិធីផ្សេងៗ ដើម្បីអភិវឌ្ឍន៍ នៅថ្នាក់ក្រោមជាតិ ។

## ១.៣ វិធីសាស្ត្រនៃការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ គឺធ្វើឡើយដោយមន្ត្រីនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងមានការចូលរួមពីមន្ត្រីមន្ទីរផែនការខេត្តទាំង៥ ដោយប្រើប្រាស់កម្រងសំណួរស្ថិតិ ថ្នាក់ក្រោមជាតិ ចុះសម្ភាសន៍ផ្ទាល់ជាមួយប្រធានភូមិ គ្រប់ភូមិទាំងអស់ក្នុងខេត្តទាំង៥ ដែលមានរយៈ ពេល១៥ ថ្ងៃ គឺចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ។ កាលបរិច្ឆេទយោងគឺរយៈពេល១២ ខែកន្លងមក គឺចាប់ពី ខែមីនា ឆ្នាំ២០១៧ ដល់ខែមីនា ឆ្នាំ២០១៨ ។

## ១.៤ ការកែច្នៃទិន្នន័យ

ទិន្នន័យនេះ គឺត្រូវបានធ្វើការកែច្នៃដោយដៃ និងវាយបញ្ចូលនៅក្នុងកុំព្យូទ័រដោយប្រើប្រាស់តែ កម្មវិធី CSPro ប៉ុន្តែបានប្រើប្រាស់កម្មវិធីចំនួន៣ សម្រាប់ធ្វើជាតារាង និងវិភាគទិន្នន័យគឺ CSPro, Excel និង SPSS ។ ចំពោះការវាយអត្ថបទកម្មវិធី Microsoft Word ត្រូវបានយកមកប្រើប្រាស់ផងដែរ ការវាយបញ្ចូលទិន្នន័យ និងវិភាគទិន្នន័យមានរយៈពេល០២ខែ គឺចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៨ បន្ទាប់ពីការចុះស្រង់ទិន្នន័យតាមមូលដ្ឋានរួចមក ។

# ជំពូក ២
# ការវិភាគទិន្នន័យ

គោលបំណងសំខាន់ នៃរបាយការណ៍ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ គឺផ្តល់ទិន្នន័យដែលជាតម្រូវការចាំបាច់សម្រាប់បម្រើសេចក្តីត្រូវការ៖

១. សម្រាប់ធ្វើគោលនយោបាយអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ

២. សម្រាប់ប្រើប្រាស់ក្នុងវិទ្យាស្ថានជាតិស្ថិតិ

៣. សម្រាប់ប្រើប្រាស់នៅក្នុងខេត្តសាមី

៤. សម្រាប់តម្រូវការអ្នកសិក្សាស្រាវជ្រាវ សាស្ត្រាចារ្យ និស្សិត...

ក្នុងជំពូកទី២ បង្ហាញនូវទិន្នន័យដែលទាក់ទងទៅនឹងព័ត៌មានផ្នែកប្រជាសាស្ត្រ ផ្នែកសេដ្ឋកិច្ចសង្គមកិច្ច ផ្នែកសេវាសុខាភិបាល និងអប់រំ និងផ្នែកកសិកម្ម ។

## ២.១ ព័ត៌មានប្រជាសាស្ត្រ

ចំនួនគ្រួសារ និងប្រជាជននៅក្នុងខេត្តទាំង៥ (គិតត្រឹមថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៨) រួមមាន៖ **ខេត្តក្រចេះ** មានចំនួន ៨៥.៩១៣ គ្រួសារ និងមានចំនួនប្រជាជនសរុប ៣៥១.៥៦៦ នាក់ **ខេត្តមណ្ឌលគិរី** មានចំនួន ២០.២៧៣ គ្រួសារ និងមានចំនួនប្រជាជនសរុប ៧៤.៦១១ នាក់ **ខេត្តព្រះវិហារ** មានចំនួន ៥៨.៧១៨ គ្រួសារ និងមានចំនួនប្រជាជនសរុប ២៣៩.៩៥២ នាក់ **ខេត្តរតនគិរី** មានចំនួន ៤៩.៨៧២ គ្រួសារ និងមានប្រជាជនសរុបចំនួន ២០៤.៣៨៧ នាក់ **ខេត្តស្ទឹងត្រែង** មានចំនួន ៣៥.៧៨៣ គ្រួសារ និងមានប្រជាជនសរុបចំនួន ១០៩.០២០ នាក់ ។

**តារាង១: ចំនួនប្រជាជន និងគ្រួសារ**

| ចំនួនសរុប | ក្រចេះ | មណ្ឌលគិរី | ព្រះវិហារ | រតនគិរី | ស្ទឹងត្រែង |
|---|---|---|---|---|---|
| គ្រួសារ | 85,913 | 20,273 | 58,718 | 49,872 | 35,783 |
| ប្រជាជន | 351,566 | 74,611 | 239,952 | 204,387 | 109,020 |

ក្រាហ្វិក១: ភាគរយស្ត្រីជាមេគ្រួសារ និងគ្រួសារដែលមានស្ត្រីកូនក្រោម៥ឆ្នាំតាមខេត្ត




ក្រាហ្វិក១ បានបង្ហាញថា៖ **ខេត្តស្ទឹងត្រែង** ក្នុងចំណោមមេគ្រួសារសរុប ៣៥.៧៨៣ គ្រួសារ មានមេគ្រួសារជាស្ត្រី ៧.៥ % និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ មានកូនអាយុក្រោម៥ឆ្នាំ ២.១% **ខេត្តរតនៈគិរី** ក្នុងចំណោមមេគ្រួសារសរុប ៤៩.៨៧២ គ្រួសារ មានមេគ្រួសារជាស្ត្រី ៧.៨ % និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ មានកូនអាយុក្រោម៥ឆ្នាំ ២.០% **ខេត្តព្រះវិហារ** ក្នុងចំណោមមេគ្រួសារសរុប ៥៨.៧១៨ គ្រួសារ មានមេគ្រួសារជាស្ត្រី ១៣.៣% និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ មានកូនអាយុក្រោម៥ឆ្នាំ ០.៤% **ខេត្តមណ្ឌលគិរី** ក្នុងចំណោមមេគ្រួសារសរុប ២០.២៧៣ គ្រួសារ មានមេគ្រួសារជាស្ត្រី ៨.៤% និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ មានកូនអាយុក្រោម៥ឆ្នាំ ០.៦% **ខេត្តក្រចេះ** ក្នុងចំណោមមេគ្រួសារសរុប ៨៥.៩១៣ គ្រួសារ មានមេគ្រួសារជាស្ត្រី ១០.៥% និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ មានកូនអាយុក្រោម៥ឆ្នាំ ៣.៣% ។ ក្នុងចំណោមបណ្ដាខេត្តទាំង៥ គឺ**ខេត្តក្រចេះ** គ្រួសារដែលមានស្ត្រីជាមេគ្រួសារ មានកូនអាយុក្រោម៥ឆ្នាំ ៣.៣% ជាភាគរយដែលខ្ពស់ជាងគេ និងខេត្តដែលមានស្ត្រីជាមេគ្រួសារ មានភាគរយខ្ពស់ជាងគេក្នុង**ខេត្តព្រះវិហារ** ១៣.៣%។

## ២.១.២ ព័ត៌មានពីប្រជាជន

### ក. គ្រួសារតាមជនជាតិ

ក្រាហ្វិក២: ភាគរយគ្រួសារតាមជនជាតិ និងតាមខេត្តទាំង៥




ក្រាហ្វិក២ បានបង្ហាញថា៖ ក្នុងចំណោមគ្រួសារសរុបក្នុងខេត្តទាំង៥ (ក្នុងនោះមិនរាប់បញ្ចូលគ្រួសារដែលជាជនជាតិខ្មែរ យកតែជនជាតិដែលមានភាគរយបួនលំដាប់ប៉ុណ្ណោះ) **ខេត្តស្ទឹងត្រែង** ក្នុងចំណោមគ្រួសារសរុប ៣៥.៧៨៣ គ្រួសារ ដែលមានភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺជនជាតិដើមភាគតិច ៣.៥% ជនជាតិខ្មែរឥស្លាម ២.២% ជនជាតិឡាវ ០.២% និងជនជាតិវៀតណាម ០.១% ។ **ខេត្តរតនៈគីរី** ក្នុងចំណោមគ្រួសារសរុប ៤៩.៨៧២ គ្រួសារ ដែលមានភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺជនជាតិដើមភាគតិច ៣០% ជនជាតិឡាវ ០.៤% និងជនជាតិវៀតណាម និងខ្មែរឥស្លាម ០.១% ។ **ខេត្តព្រះវិហារ** ក្នុងចំណោមគ្រួសារសរុប ៥៨.៧១៨ គ្រួសារ ដែលមានភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺជនជាតិដើមភាគតិច ៤.១% និងជនជាតិឡាវ ០.២% ។ **ខេត្តមណ្ឌលគីរី** ក្នុងចំណោមគ្រួសារសរុប ២០.២៧៣ គ្រួសារ ដែលមានភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺ ជនជាតិដើមភាគតិច ២២% ជនជាតិខ្មែរឥស្លាម ២.២% និងជនជាតិឡាវ ០.៧% ។ **ខេត្តក្រចេះ** ក្នុងចំណោមគ្រួសារសរុប ៨៥.៩១៣

គ្រួសារ ដែលមានភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺជនជាតិដើមភាគតិច ៥.៥% ខ្មែរឥស្លាម ៣.៧% និងជនជាតិវៀតណាម ០.២% ។

### ខ. ស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារ



ក្រាហ្វិក៣: ភាគរយស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារតាមខេត្តទាំង៥

ក្រាហ្វិក៣ បានបង្ហាញថា៖ ស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារ សរុបក្នុងខេត្តទាំង៥មាន៖ **ខេត្តស្ទឹងត្រែង** មេគ្រួសារសរុប ៣៥.៧៨៣ គ្រួសារ ក្នុងនោះមេគ្រួសារដែលបានរៀបការរស់នៅជាមួយគ្នា ៨៧.៣% មេម៉ាយ ឬពោះម៉ាយ ៩.២% រស់នៅផ្សេងគ្នា ០.៤% រស់នៅជាមួយគ្នាមិនបានរៀបការ ២.៥% និងមិនដែលរៀបការ ០.៦% **ខេត្តរតនៈគិរី** មេគ្រួសារសរុប ៤៩.៨៧២ គ្រួសារ ក្នុងនោះមេគ្រួសារដែលបានរៀបការរស់នៅជាមួយគ្នា ៨៧.៨% មេម៉ាយ ឬពោះម៉ាយ ៣.១% រស់នៅផ្សេងគ្នា ១.៨% រស់នៅជាមួយគ្នាមិនបានរៀបការ ១.៩% និងមិនដែលរៀបការ ៦.៤% **ខេត្តព្រះវិហារ** មេគ្រួសារសរុប ៥៨.៧១៨ គ្រួសារ ក្នុងនោះមេគ្រួសារដែលបានរៀបការរស់នៅជាមួយគ្នា ៩០% មេម៉ាយ ឬពោះម៉ាយ ៨.២% រស់នៅផ្សេងគ្នា ០.៩% រស់នៅជាមួយគ្នាមិនបានរៀបការ ០.៩% និងមិនដែលរៀបការ ០.១% **ខេត្តមណ្ឌលគិរី** មេគ្រួសារសរុប ២០.២៧៣ គ្រួសារ ក្នុងនោះមេគ្រួសារដែលបានរៀប

ការរស់នៅជាមួយគ្នា ៨៨.៧% មេម៉ាយ ឬពោះម៉ាយ ៩.១% រស់នៅផ្សេងគ្នា ០.២% រស់នៅជាមួយគ្នាមិនបានរៀបការ ១.៦% និងមិនដែលរៀបការ ០.៤% **ខេត្តក្រចេះ** មេគ្រួសារសរុប ៨៥.៩១៣ គ្រួសារ ក្នុងនោះមេគ្រួសារដែលបានរៀបការរស់នៅជាមួយគ្នា ៤៣.៥% មេម៉ាយ ឬពោះម៉ាយ ៩.១% រស់នៅផ្សេងគ្នា ០.៥% រស់នៅជាមួយគ្នាមិនបានរៀបការ ៤៥.៧% និងមិនដែលរៀបការ ១.៣%។

### ២.១.៣ ប្រជាជនធ្វើការបំលាស់ប្តូរទីលំនៅ

#### ក. គ្រួសារធ្វើចំណាកស្រុកចេញ និងចំណូលស្រុក




ក្រាហ្វិក៤ បានបង្ហាញថា៖ ស្ថានភាពការធ្វើចំណាកស្រុករបស់គ្រួសារក្នុងចំណោមគ្រួសារសរុបក្នុងខេត្តទាំង៥រួមមាន៖ **ខេត្តស្ទឹងត្រែង** ក្នុងចំណោមគ្រួសារសរុបចំនួន ៣៥.៧៨៣ គ្រួសារ មានគ្រួសារធ្វើចំណាកស្រុកចំនួន ៣៥០ គ្រួសារ និងគ្រួសារចំណូលស្រុកចំនួន ១.៧៧៦ គ្រួសារ **ខេត្តរតនៈគិរី** ក្នុងចំណោមគ្រួសារសរុបចំនួន ៤៩.៨៧២ គ្រួសារ មានគ្រួសារធ្វើចំណាកស្រុកចំនួន ២៦៣ គ្រួសារ និងគ្រួសារចំណូលស្រុកចំនួន ៤៩៣ គ្រួសារ **ខេត្តព្រះវិហារ** ក្នុងចំណោមគ្រួសារសរុបចំនួន ៥៨.៧១៨ គ្រួសារ មានគ្រួសារធ្វើចំណាកស្រុកចំនួន ៧៦៩ គ្រួសារ និងគ្រួសារចំណូលស្រុកចំនួន ៥២៧ គ្រួសារ

**ខេត្តមណ្ឌលគិរី** ក្នុងចំណោមគ្រួសារសរុបចំនួន ២០.២៧៣ គ្រួសារ មានគ្រួសារធ្វើចំណាកស្រុកចំនួន ១០៤ គ្រួសារ និងគ្រួសារចំណូលស្រុកចំនួន ១៩៨ គ្រួសារ **ខេត្តក្រចេះ** ក្នុងចំណោមគ្រួសារសរុបចំនួន ៨៥.៩១៣ គ្រួសារ មានគ្រួសារធ្វើចំណាកស្រុកចំនួន ២.៨៤៣ គ្រួសារ និងគ្រួសារចំណូលស្រុកចំនួន ២.៤១២ គ្រួសារ នៅក្នុងចំណោមខេត្តទាំង៥ គ្រួសារដែលធ្វើចំណាកស្រុកច្រើនជាងគឺ **ខេត្តក្រចេះ**ដែលមានចំនួនរហូតទៅដល់ **២.៨៤៣** គ្រួសារ ។

## ខ. មូលហេតុគ្រួសារធ្វើចំណាកស្រុកក្នុង និងក្រៅប្រទេស




ក្រាហ្វិក៥ បានបង្ហាញថា៖ ស្ថានភាពការធ្វើចំណាកស្រុករបស់គ្រួសារក្នុងចំណោមគ្រួសារសរុបក្នុងខេត្តទាំង៥រួមមាន៖ **ខេត្តស្ទឹងត្រែង** មចំនួនគ្រួសារសរុប ៣៥.៧៨៣ គ្រួសារ មានគ្រួសារធ្វើចំណាកស្រុកទៅស្វែងរកការងារក្រៅប្រទេសស្មើនឹង ៤២១ គ្រួសារ និងគ្រួសារធ្វើចំណាកស្រុកទៅស្វែងរកការងារក្នុងប្រទេសស្មើនឹង ៨១១ គ្រួសារ **ខេត្តរតនៈគិរី** ចំនួនគ្រួសារសរុប ៤៩.៨៧២ គ្រួសារ មានគ្រួសារធ្វើចំណាកស្រុកទៅស្វែងរកការងារក្រៅប្រទេសស្មើនឹង ១៦០ គ្រួសារ និងគ្រួសារធ្វើចំណាក

ស្រុកទៅស្វែងរកការងារក្នុងប្រទេសស្មើនឹង ៣៦៣ គ្រួសារ **ខេត្តព្រះវិហារ** ចំនួនគ្រួសារសរុប ៥៨.៧១៨ គ្រួសារ មានគ្រួសារធ្វើចំណាកស្រុកទៅស្វែងរកការងារក្រៅប្រទេសស្មើនឹង ១.៣៩២ គ្រួសារ និងគ្រួសារធ្វើចំណាកស្រុកទៅស្វែងរកការងារក្នុងប្រទេសស្មើនឹង ១.០៨២ គ្រួសារ **ខេត្តមណ្ឌលគិរី** ចំនួនគ្រួសារសរុប ២០.២៧៣ គ្រួសារ មានគ្រួសារធ្វើចំណាកស្រុកទៅស្វែងរកការងារក្រៅប្រទេសស្មើនឹង ១០០ គ្រួសារ និងគ្រួសារធ្វើចំណាកស្រុកទៅស្វែងរកការងារក្នុងប្រទេសស្មើនឹង ២៣៦ គ្រួសារ និង**ខេត្តក្រចេះ** ចំនួនគ្រួសារសរុប ៨៥.៩១៣ គ្រួសារ មានគ្រួសារធ្វើចំណាកស្រុកទៅស្វែងរកការងារក្រៅប្រទេសស្មើនឹង ២.០២៣ គ្រួសារ និងគ្រួសារធ្វើចំណាកស្រុកទៅស្វែងរកការងារក្នុងប្រទេសស្មើនឹង ៥.៥១០ គ្រួសារ ។

### គ. ពលករចំណាកស្រុកក្នុងប្រទេស និងក្រៅប្រទេស

តារាង២: ចំនួនពលករធ្វើចំណាកស្រុកក្នុងប្រទេស និងក្រៅប្រទេសចែកតាមខេត្ត

| ពលករចំណាកស្រុក | ក្រចេះ | មណ្ឌលគិរី | ព្រះវិហារ | រតនៈគិរី | ស្ទឹងត្រែង |
|---|---|---|---|---|---|
| នៅក្នុងប្រទេស | 9,526 | 524 | 1,549 | 741 | 1,347 |
| នៅក្រៅប្រទេស | 3,077 | 147 | 1,854 | 193 | 978 |
| **សរុប** | **12,603** | **671** | **3,403** | **934** | **2,325** |

តារាង២ បានបង្ហាញថា៖ ស្ថានភាពពលករធ្វើចំណាកស្រុកក្នុងប្រទេស និងក្រៅប្រទេសរួមមាន៖ **ខេត្តស្ទឹងត្រែង** មានពលករសរុបចំនួន ២.៣២៥ នាក់ ពលករទៅស្វែងរកការងារក្រៅប្រទេសចំនួន ៩៧៨ នាក់ និងពលករទៅស្វែងរកការងារក្នុងប្រទេសចំនួន ១.៣៤៧ នាក់ **ខេត្តរតនៈគិរី** មានពលករសរុបចំនួន ៩៣៤ នាក់ ពលករទៅស្វែងរកការងារក្រៅប្រទេសចំនួន ១៩៣ នាក់ និងពលករទៅស្វែងរកការងារក្នុងប្រទេសចំនួន ៧៤១ នាក់ **ខេត្តព្រះវិហារ** មានពលករសរុបចំនួន ៣.៤០៣ នាក់ ពលករទៅស្វែងរកការងារក្រៅប្រទេសចំនួន ១.៨៥៤ នាក់ និងពលករទៅស្វែងរកការងារក្នុងប្រទេសចំនួន ១.៥៤៩ នាក់ **ខេត្តមណ្ឌលគិរី** មានពលករសរុបចំនួន ៦៧១ នាក់ ពលករទៅស្វែងរកការងារក្រៅប្រទេសចំនួន ១៤៧ នាក់ និងពលករទៅស្វែងរកការងារក្នុងប្រទេសចំនួន ៥២៤ នាក់ **ខេត្តក្រចេះ** មានពលករសរុបចំនួន ១២.៦០៣ នាក់ ពលករទៅស្វែងរកការងារក្រៅប្រទេសចំនួន ៣.០៧៧ នាក់ និងពលករទៅស្វែងរកការងារក្នុងប្រទេសចំនួន ៩.៥២៦ នាក់ ។

## ឃ. ចំនួនពលករទៅស្វែងរកការងារក្នុងប្រទេស និងក្រៅប្រទេសបែងចែងតាមភេទ

### ១. ក្នុងប្រទេស




ក្រាហ្វិក៦ បានបង្ហាញថា៖ ចំនួនពលករបានធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើក្នុងប្រទេស **ខេត្តក្រចេះ** ក្នុងចំណោមពលករសរុបចំនួន ៩.៥២៦ នាក់ មានពលការិនីចំនួន ៥២.៤% **ខេត្តមណ្ឌលគិរី** ក្នុងចំណោមពលករសរុបចំនួន ៥២៤ នាក់ មានពលការិនីចំនួន ៤៩.២% **ខេត្តព្រះវិហារ** ក្នុងចំណោមពលករសរុបចំនួន ១.៥៤៩ នាក់ មានពលការិនីចំនួន ៥២.៧% **ខេត្តរតនៈគិរី** ក្នុងចំណោមពលករសរុបចំនួន ៧៤១ នាក់ មានពលការិនីចំនួន៤១.៣% **ខេត្តស្ទឹងត្រែង** ក្នុងចំណោមពលករសរុបចំនួន ១.៣៤៧ នាក់ មានពលការិនីចំនួន ៤៦.៨% ។

## ២. ក្រៅប្រទេស




ក្រាហ្វិក៧ បានបង្ហាញថាៈចំនួនពលករបានធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើក្រៅប្រទេស **ខេត្តក្រចេះ** ក្នុងចំណោមពលករសរុបចំនួន ៩.៥២៦ នាក់ មានពលការិនីចំនួន ៤៩.២% **ខេត្តមណ្ឌលគិរី** ក្នុងចំណោមពលករសរុបចំនួន ៥២៤ នាក់ មានពលការិនីចំនួន ៣២.៧% **ខេត្តព្រះវិហារ** ក្នុងចំណោមពលករសរុបចំនួន ១.៥៤៩ នាក់ មានពលការិនីចំនួន ៤៧.១% **ខេត្តរតនៈគិរី** ក្នុងចំណោមពលករសរុបចំនួន ៧៤១ នាក់ មានពលការិនីចំនួន ៤៧.៧% **ខេត្តស្ទឹងត្រែង** ក្នុងចំណោមពលករសរុបចំនួន ១.៣៤៧ នាក់ មានពលការិនីចំនួន ៤៨.៥% ។

## ២.១.៤ លំនៅដ្ឋាន

### ក. ប្រភេទនៃដំបូលផ្ទះរបស់គ្រួសារ

### តារាង៣: ប្រភេទនៃដំបូលផ្ទះ

| ប្រភេទនៃដំបូលផ្ទះ | ក្រចេះ | | មណ្ឌលគិរី | | ព្រះវិហារ | | រតនៈគិរី | | ស្ទឹងត្រែង | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| បេតុង | 1,560 | 1.9 | 58 | 0.3 | 272 | 0.5 | 142 | 0.4 | 974 | 3.1 |
| ក្បឿង | 36,927 | 44.1 | 1,920 | 10.1 | 9,789 | 19.5 | 2,670 | 7.1 | 1,589 | 5.1 |
| ស័ង្កសី / ហ្វីប្រូ | 38,322 | 45.8 | 15,586 | 81.9 | 36,449 | 72.6 | 33,211 | 87.9 | 26,700 | 85.4 |
| ប្រក់ស្លឹក | 4,777 | 5.7 | 595 | 3.1 | 3,521 | 7.0 | 765 | 2.0 | 1,829 | 5.9 |
| ផ្សេងទៀត | 2,103 | 2.5 | 872 | 4.6 | 185 | 0.4 | 992 | 2.6 | 159 | 0.5 |
| **សរុប** | **83,689** | **100** | **19,031** | **100** | **50,216** | **100** | **37,780** | **100** | **31,251** | **100** |

តារាង៣ បានបង្ហាញពីភាគរយ នៃដំបូលផ្ទះរបស់ប្រជាពលរដ្ឋតាមខេត្តទាំង៥ ពីច្រើនទៅតិច តាមលំដាប់៖ **ខេត្តរតនៈគិរី** ដំបូលផ្ទះប្រក់អំពីស័ង្កសី/ហ្វីប្រូ ខ្ពស់ជាងគេមាន ៨៧.៩% បន្ទាប់មក**ខេត្តស្ទឹងត្រែង** ៨៥.៤% **ខេត្តមណ្ឌលគិរី** ៨១.៩% **ខេត្តព្រះវិហារ** ៧២.៦% និង**ខេត្តក្រចេះ** ៤៥.៨% ចំណែកផ្ទះដំបូលប្រក់អំពីស្លឹក ភាគរយដែលខ្ពស់ជាងគេគឺ **ខេត្តព្រះវិហារ** ៧% បន្ទាប់មក**ខេត្តស្ទឹងត្រែង** ៥.៩% **ខេត្តក្រចេះ** ៥.៧% **ខេត្តមណ្ឌលគិរី** ៣.១% និង**ខេត្តរតនៈគិរី** ២ % ។

## ខ. ការប្រើប្រាស់អគ្គិសនីតាមប្រភេទនៃដំបូលផ្ទះ



ក្រាហ្វិក៨: ភាគរយគ្រួសារមានអគ្គិសនីប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ និងតាមខេត្ត

ក្រាហ្វិក៨ បានបង្ហាញថាពីការប្រើប្រាស់អគ្គិសនីខេត្តទាំង៥៖ គ្រួសារដែលមានដំបូលផ្ទះប្រក់អំពីស័ង្កសី/ហ្វីប្រូ និងមានអគ្គិសនីប្រើប្រាស់នៅ **ខេត្តស្ទឹងត្រែង** មានចំនួនរហូតទៅដល់ ៨៣.១% **ខេត្តរតនៈគីរី** មានចំនួន ៧៩.៩% **ខេត្តមណ្ឌលគីរី** មានចំនួន ៧៨.៦% និង**ខេត្តព្រះវិហារ** មានចំនួន ៦៨.៨% ចំណែកក្នុង **ខេត្តក្រចេះ** វិញគ្រួសារដែលមានដំបូលផ្ទះប្រក់អំពីក្បឿង និងមានអគ្គិសនីប្រើប្រាស់ មានចំនួន ៥៧.១% ។

## គ. គ្រួសារដែលមានទូរទស្សន៍ប្រើប្រាស់ប្រភេទនៃដំបូលផ្ទះ

ក្រាហ្វិក៩: ភាគរយនៃគ្រួសារមានទូរទស្សន៍ប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ និងតាមខេត្ត




ក្រាហ្វិក៩ បានបង្ហាញថា៖ គ្រួសារដែលមានទូរទស្សន៍ប្រើប្រាស់ស្របជាមួយ និងការប្រើប្រាស់អគ្គិសនីមានគ្រប់ខេត្តទាំង៥ របស់គ្រួសារក្នុង **ខេត្តស្ទឹងត្រែង** ខ្ពស់ជាងគេដែលមានផ្ទះដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូ មានរហូតទៅដល់ ៧៩.៩% និងគ្រួសារដែលមានផ្ទះដំបូលប្រក់អំពីស្លឹកត្រឹមតែ ០.៥% ប៉ុណ្ណោះ ។ ដោយឡែកនៅក្នុង **ខេត្តរតនៈគិរី** វិញគ្រួសារដែលមានទូរទស្សន៍ប្រើប្រាស់ ដែលមានផ្ទះដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូ មានតែ ៧៨.៥% និងគ្រួសារដែលមានផ្ទះដំបូលប្រក់អំពីស្លឹក និងមានទូរទស្សន៍ប្រើប្រាស់ ០.៨% ប៉ុណ្ណោះ ។ **ខេត្តមណ្ឌលគិរី** គ្រួសារដែលមានទូរទស្សន៍ប្រើប្រាស់ ដែលមានផ្ទះដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូមាន ៧២.៨% ចំណែកគ្រួសារដែលមានផ្ទះដំបូលប្រក់អំពីស្លឹក និងមានទូរទស្សន៍ប្រើប្រាស់មានតែ ០.៤% ។ **ខេត្តព្រះវិហារ** គ្រួសារដែលមានទូរទស្សន៍ប្រើប្រាស់ ដែលមានផ្ទះដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូមាន ៦៤.១% ចំណែកគ្រួសារដែលមានផ្ទះដំបូលប្រក់អំពីស្លឹក និងមានទូរទស្សន៍ប្រើប្រាស់មាន ១.៣% ។ ដោយឡែក **ខេត្តក្រចេះ** ចំពោះគ្រួសារដែលមានផ្ទះដំបូលក្បឿង និងមានទូរទស្សន៍ប្រើប្រាស់រហូតទៅដល់ ៥២.៤% និងគ្រួសារដែលមានផ្ទះដំបូលប្រក់អំពីស្លឹក និងមានទូរទស្សន៍ប្រើប្រាស់ត្រឹមតែ ១.២% ប៉ុណ្ណោះ។

## ឃ. គ្រួសារដែលមានកុំព្យូទ័រប្រើប្រាស់ប្រភេទនៃដំបូលផ្ទះ

ក្រាហ្វិក១០: ភាគរយនៃគ្រួសារមានកុំព្យូទ័រប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ និងតាមខេត្ត




ក្រាហ្វិក១០ បានបង្ហាញពីគ្រួសារដែលមានកុំព្យូទ័រប្រើប្រាស់ស្រដៀងគ្នាជាមួយនិង គ្រួសារដែលមានអគ្គិសនីប្រើប្រាស់នៅតាមផ្ទះផងដែរ។

## ង. គ្រួសារដែលមានទូរស័ព្ទដៃប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ

ក្រាហ្វិក១១: ភាគរយនៃគ្រួសារមានទូរស័ព្ទប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ និងតាមខេត្ត




ក្រាហ្វិក១១ បានបង្ហាញថា៖ ភាគរយដែលខ្ពស់ជាងគេរបស់គ្រួសារ នៃប្រភេទដំបូលផ្ទះរបស់ប្រជាពលរដ្ឋតាមបណ្តាលខេត្តទាំង៥ ដែលមានដំបូលផ្ទះប្រក់អំពីស័ង្កសី/ហ្វីប្រូ និងមានទូរស័ព្ទប្រើប្រាស់ដែលមានភាគរយខ្ពស់ជាងគេក្នុង **ខេត្តរតនៈគិរី** មានចំនួន ៨៧.៣% បន្ទាប់មក **ខេត្តស្ទឹងត្រែង** មានចំនួន៧៩.៨% **ខេត្តមណ្ឌលគិរី** ៧៩.៦មានចំនួន % **ខេត្តព្រះវិហារ** មានចំនួន ៦៩.១% ដោយឡែកនៅក្នុង **ខេត្តក្រចេះ** វិញគ្រួសារមានដំបូលផ្ទះប្រក់អំពីក្បឿង និងមានទូរស័ព្ទប្រើប្រាស់មានភាគរយខ្ពស់ជាគេវិញគឺចំនួន ៤៩.២% ។

### ២.១.៥ សម្ភារៈបរិក្ខារដែលទាក់ទងការដឹកជញ្ជូន គ្រឿងម៉ាស៊ីន និងយានយន្ត

**តារាង៤: ប្រភេទបរិក្ខារតាមប្រភេទ និងតាមខេត្ត**

| ប្រភេទនៃបរិក្ខារ | ក្រចេះ | | មណ្ឌលគិរី | | ព្រះវិហារ | | រតនៈគិរី | | ស្ទឹងត្រែង | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| កសិកម្ម និងនេសាទ | 69,811 | 46.4 | 4,107 | 16.2 | 24,674 | 40.2 | 5,838 | 10.7 | 14,135 | 30.9 |
| សេវាដឹកជញ្ជូន | 8,744 | 5.8 | 698 | 2.7 | 679 | 1.1 | 1,061 | 1.9 | 3,214 | 7.0 |
| សេវាដឹកជញ្ជូន និងប្រើប្រាស់ផ្ទាល់ខ្លួន | 71,743 | 47.7 | 20,622 | 81.1 | 36,081 | 58.7 | 47,561 | 87.3 | 28,368 | 62.1 |
| **សរុប** | **150,298** | **100** | **25,427** | **100** | **61,434** | **100** | **54,460** | **100** | **45,717** | **100** |

តារាង៤ បានបង្ហាញថា៖ ចំនួនភាគរយនៃការប្រើប្រាស់ប្រភេទបរិក្ខារកសិកម្ម និងនេសាទ ក្នុង **ខេត្តក្រចេះ** មានចំនួន ៦៩.៨១១ ស្មើនឹង ៤៦.៤% **ខេត្តមណ្ឌលគិរី** មានចំនួន ៤.១០៧ ស្មើនឹង ១៦.២ % **ខេត្តព្រះវិហារ** មានចំនួន ២៤.៦៧៤ ស្មើនឹង ៤០.២% **ខេត្តរតនៈគិរី** មានចំនួន ៥.៨៣៨ ស្មើនឹង ១០.៧% និង**ខេត្តស្ទឹងត្រែង** មានចំនួន ១៤.១៣៥ ស្មើនឹង ៣០.៩% ដូចនេះក្នុងចំណោមខេត្តទាំង៥ គឺ**ខេត្តក្រចេះ** មានភាគរយនៃការប្រើប្រាស់ប្រភេទបរិក្ខារកសិកម្ម និងនេសាទច្រើនជាងគេ ដែលមានរហូតទៅដល់ **៤៦.៤%** ។

## ក. ប្រភេទនៃបរិក្ខារសម្រាប់ប្រើប្រាស់ក្នុងផ្នែកកសិកម្ម និងនេសាទ

**ក្រាហ្វិក១២: ភាគរយប្រភេទនៃបរិក្ខារកសិកម្ម និងនេសាទតាមខេត្ត**




ក្រាហ្វិក១២ បានបង្ហាញថា៖ **ខេត្តព្រះវិហារ** ប្រើប្រាស់ឧបករណ៍កសិកម្ម និងគ្រឿងម៉ាស៊ីនភ្ជួររាស់ មានភាគរយខ្ពស់ជាងគេរហូតដល់ ៩៧.១% ចំណែកការប្រើប្រាស់រទេះគោ និងសេះមានត្រឹមតែ ០.១% ប៉ុណ្ណោះ។ **ខេត្តរតនៈគិរី** ប្រើប្រាស់ឧបករណ៍កសិកម្ម និងគ្រឿងម៉ាស៊ីនភ្ជួររាស់ មានភាគរយខ្ពស់បន្ទាប់ ៨១.៣% និងមិនមានការប្រើប្រាស់កំលាំងអូសទាញដោយរទេះគោ និងសេះទេ។ **ខេត្តមណ្ឌលគិរី** មានការប្រើប្រាស់ឧបករណ៍កសិកម្ម និងគ្រឿងម៉ាស៊ីនភ្ជួររាស់ ៨០.៨% ដោយឡែកការប្រើប្រាស់កំលាំងអូសទាញដោយរទេះគោ និងសេះមានត្រឹមតែ ២.៥% ប៉ុណ្ណោះ ។ **ខេត្តស្ទឹងត្រែង** ប្រើប្រាស់ឧបករណ៍កសិកម្ម និងគ្រឿងម៉ាស៊ីនភ្ជួររាស់ ៥៩.៣% និងពុំមានការប្រើប្រាស់កំលាំងអូសទាញដោយរទេះគោ និងសេះទេ ហើយមានការប្រើប្រាស់ទូកនេសាទ រហូតដល់ ៣៤.២% ។ **ខេត្តក្រចេះ** វិញ មានការប្រើប្រាស់ឧបករណ៍កសិកម្មផ្សេងៗទៀតរហូតដល់ ៦៦.១% និងមានការប្រើប្រាស់កំលាំងអូសទាញដោយរទេះគោ និងសេះ ៥.១% ផងដែរ ។

## ខ. ប្រភេទនៃសេវាដឹកជញ្ជូន




ក្រាហ្វិក១៣ បានបង្ហាញថា៖ ភាគរយនៃប្រភេទការប្រើប្រាស់សេវាដឹកជញ្ជូនដោយទូក មានភាគរយខ្ពស់ជាងគេក្នុង**ខេត្តស្ទឹងត្រែង** ៨៤.៤% និង**ខេត្តក្រចេះ** ៦៨.៨% ចំពោះ**ខេត្តរតនៈគិរី** ភាគរយនៃប្រភេទការប្រើប្រាស់សេវាដឹកជញ្ជូនដោយរថយន្តដឹកទំនិញ ៦១.៦% **ខេត្តព្រះវិហារ** ៥៤.១% និង**ខេត្តមណ្ឌលគិរី** ត្រឹមតែ ៤៦.៨% ប៉ុណ្ណោះ។

## គ. បរិក្ខារសេវាដឹកជញ្ជូនសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន




ក្រាហ្វិក១៤ បានបង្ហាញថា៖ បរិក្ខារសេវាដឹកជញ្ជូន និងសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនដោយម៉ូតូមានភាគរយខ្ពស់គ្រប់ខេត្តទាំង៥ **ខេត្តក្រចេះ** ៩៥.១% **ខេត្តមណ្ឌលគិរី** ៩៣% **ខេត្តស្ទឹងត្រែង** ៩២.៩% ខេត្តព្រះវិហារ ៩២.៦% និងខេត្តរតនៈគិរី ៩២.១% ។ ចំពោះបរិក្ខារសេវាដឹកជញ្ជូន និង សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ដោយរថយន្តលក្ខណៈគ្រួសារក៏មានគ្រប់ខេត្តទាំង៥ផងដែរ **ខេត្តមណ្ឌលគិរី** ៦.៨% **ខេត្តព្រះវិហារ** ៥.៧% **ខេត្តស្ទឹងត្រែង** ៥.៦% **ខេត្តរតនៈគិរី** ៥.២% និង**ខេត្តក្រចេះ** ៤.៣% ។

# ២.២. អត្រាកំណើត និងមរណភាព

## ២.២.១ អត្រាកំណើត

### ក. ទីកន្លែងទារកកើតក្នុងរយៈពេល១២ខែកន្លងមក




ក្រាហ្វិក១៥ បានបង្ហាញថា៖ ភាគរយរបស់ទារកដែលបានកើតក្នុងរយៈពេល១២ខែកន្លងមកតាមខេត្តទាំង៥មាន៖ **ខេត្តក្រចេះ** ទារកដែលបានកើតសរុបចំនួន ៥.៩៧៧ នាក់ ក្នុងនោះទារកដែលបានកើតក្នុងមន្ទីរពេទ្យរដ្ឋមាន ៤.៨៤៤ នាក់ស្មើនឹង ៨១% មន្ទីរពេទ្យឯកជនមាននចំនួន ៨៧៥ នាក់ស្មើនឹង ១៤.៦% ឆ្មបបុរាណមាន ២២២ នាក់ស្មើនឹង ៣.៧% ។ **ខេត្តមណ្ឌលគិរី** ទារកដែលបានកើតក្នុងរយៈពេល១២ខែកន្លងមកសរុបចំនួន ១.៥០៥ នាក់បានកើតមន្ទីរពេទ្យរដ្ឋមានចំនួន ១.១០៤ នាក់ស្មើនឹង ៧៣.៤% មន្ទីរពេទ្យឯកជនមានចំនួន ១៩ នាក់ស្មើនឹង ១.៣% និងឆ្មបបុរាណមានចំនួន ២៩៩ នាក់ស្មើនឹង ១៩.៩% ។ **ខេត្តព្រះវិហារ** ទារកដែលបានកើតក្នុងរយៈពេល១២ខែកន្លងមកសរុបចំនួន ៣.៩៧១ នាក់បានកើតមន្ទីរពេទ្យរដ្ឋចំនួន ៣.៥៧៣ នាក់ស្មើនឹង ៩០% មន្ទីរពេទ្យឯកជនមានចំនួន ៤១ នាក់ស្មើនឹង ១% និងឆ្មបបុរាណមានចំនួន ២៤១ នាក់ស្មើនឹង ២.៩% ។ **ខេត្តរតនៈគិរី** ទារកដែលបានកើតក្នុងរយៈពេល១២ខែកន្លងមកសរុបចំនួន ៣.៤៧៥ នាក់បានកើតមន្ទីរពេទ្យរដ្ឋមានចំនួន ២.៥៤៥ នាក់ស្មើនឹង ៧៣.២% មន្ទីរពេទ្យឯកជនមានចំនួន ៨ នាក់ស្មើនឹង ០.២% និងឆ្មបបុរាណមានចំនួន ៨៤៨ នាក់ស្មើនឹង ២៤.៤% ។ **ខេត្តស្ទឹងត្រែង** ទារកដែលបានកើតក្នុងរយៈពេល១២ខែកន្លងមកសរុបចំនួន ២.៣៧០ នាក់បានកើតមន្ទីរពេទ្យរដ្ឋមានចំនួន ១.៨០៧ នាក់ស្មើនឹង ៧៦.២% មន្ទីរពេទ្យឯកជនមានចំនួន ៤៧ នាក់ស្មើនឹង ២% និងឆ្មបបុរាណមានចំនួន ៤២៤ នាក់ស្មើនឹង ១៧.៩% ។

## ខ. ទារកកើតក្នុងរយៈពេល១២ខែកន្លងមកតាមភេទ

**ក្រាហ្វិក១៦: ចំនួនទារកដែលបានកើតក្នុងរយៈពេល១២ខែកន្លងមកតាមភេទ និងខេត្តទាំង៥**




ក្រាហ្វិក១៦ បានបង្ហាញថា៖ **ខេត្តក្រចេះ** ទារកដែលបានកើតក្នុងរយៈពេល១២ខែកន្លងមកសរុបចំនួន ៥.៩៧៧ នាក់ដែលមានទារកភេទស្រីស្មើនឹង ៥២.៥% **ខេត្តមណ្ឌលគិរី** ទារកដែលបានកើតក្នុងរយៈពេល១២ខែកន្លងមកសរុបចំនួន ១.៥០៥ នាក់ដែលមានទារកភេទស្រីស្មើនឹង ៥០.២% **ខេត្តព្រះវិហារ** ទារកដែលបានកើតក្នុងរយៈពេល១២ខែកន្លងមកសរុបចំនួន ៣.៩៧១ នាក់ដែលមានទារកភេទស្រីស្មើនឹង ៥០.៥% **ខេត្តរតនៈគិរី** ទារកដែលបានកើតក្នុងរយៈពេល១២ខែកន្លងមកសរុបចំនួន ៣.៤៧៥ នាក់ដែលមានទារកភេទស្រីស្មើនឹង ៤៧.៨% **ខេត្តស្ទឹងត្រែង** ទារកដែលបានកើតក្នុង រយៈពេល១២ខែកន្លងមកសរុបចំនួន ២.៣៧០ នាក់ដែលមានទារកភេទស្រីស្មើនឹង ៦៥.៤% ។

## ២.២.២ មរណភាព

### ក. ជំងឺ

តារាង៥: មូលហេតុនៃការស្លាប់រយៈពេល១២ខែកន្លងមកតាមខេត្តទាំង៥

| មូលហេតុចម្បងនៃការស្លាប់ | ក្រចេះ | មណ្ឌលគិរី | ព្រះវិហារ | រតនៈគិរី | ស្ទឹងត្រែង |
|---|---|---|---|---|---|
| 1- ជំងឺ | 1,135 | 192 | 542 | 23 | 246 |
| 2- គ្រោះថ្នាក់ចរាចរ | 123 | 17 | 67 | 28 | 27 |
| 3- លង់ទឹក | 35 | 6 | 14 | - | 8 |
| 4- ពស់ចឹក | 8 | 1 | 3 | - | 3 |
| 5- ឃាតកម្ម | 11 | 5 | 9 | 1 | 6 |
| 6- ផ្សេងៗ | 125 | 9 | 17 | 503 | 95 |
| **សរុប** | **1,437** | **230** | **652** | **555** | **385** |

តារាង៥ និងក្រាហ្វិក១៧ បានបង្ហាញថា៖ នៅ **ខេត្តក្រចេះ** ចំនួនអ្នកស្លាប់សរុបមាន ១.៤៣៧ នាក់ ក្នុងនោះស្លាប់ដោយសារជំងឺមានចំនួន ១.១៣៥ នាក់ ស្មើនឹង ៧៩% **ខេត្តមណ្ឌលគិរី** មានចំនួនអ្នកស្លាប់ ២៣០ នាក់ ក្នុងនោះស្លាប់ដោយសារជំងឺមាន ១៩២ នាក់ ស្មើនឹង ៨៣.៥% **ខេត្តព្រះវិហារ** មានចំនួនអ្នកស្លាប់ ៦៥២ នាក់ ក្នុងនោះស្លាប់ដោយសារជំងឺមាន ៥៤២ នាក់ ស្មើនឹង ៨៣.១% **ខេត្តរតនៈគិរី** មានចំនួនអ្នកស្លាប់ ៥៥៥ នាក់ ក្នុងនោះស្លាប់ដោយសារជំងឺមាន ២៣ នាក់ ស្មើនឹង ៤.១% និង **ខេត្តស្ទឹងត្រែង** ចំនួនអ្នកស្លាប់មាន ៣៨៥ នាក់ ក្នុងនោះស្លាប់ដោយសារជំងឺមាន ២៤៦ នាក់ ស្មើនឹង ៦៣.៩% នៃចំនួនអ្នកស្លាប់ប្រចាំខេត្តនីមួយៗ ។



## ខ. គ្រោះថ្នាក់ចរាចរណ៍ និងលង់ទឹក




តារាង៥ និងក្រាហ្វិក១៨ បានបង្ហាញថា៖ នៅ **ខេត្តក្រចេះ** ចំនួនអ្នកស្លាប់សរុបមាន១.៤៣៧ នាក់ ក្នុងនោះស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ ៨.៦% និងលង់ទឹក ២.៤% **ខេត្តមណ្ឌលគិរី** ចំនួនអ្នកស្លាប់សរុបមាន ២៣០ នាក់ ក្នុងនោះស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ ៧.៤% និងលង់ទឹក ២.៦% **ខេត្តព្រះវិហារ** ចំនួនអ្នកស្លាប់សរុបមាន ៦៥២ នាក់ ក្នុងនោះស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ ១០.៣% និងលង់ទឹក ២.១% **ខេត្តរតនៈគិរី** ចំនួនអ្នកស្លាប់សរុបមាន ៥៥៥ នាក់ ក្នុងនោះស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ ៥% និងមិនមានករណីលង់ទឹក និង**ខេត្តស្ទឹងត្រែង** ចំនួនអ្នកស្លាប់សរុបមាន ៣៨៥ នាក់ ក្នុងនោះស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ ៧% និងស្លាប់ដោយសារលង់ទឹក ២.១% ។ គួរគត់សម្គាល់ឃើញថា៖ អត្រានៃការស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍នៅក្នុង**ខេត្តព្រះវិហារ** មានអត្រាស្លាប់ខ្ពស់ជាងក្នុងចំណោមខេត្តទាំង៥ ដែលមានរហូតទៅដល់ **១០.៣%**។

## គ. ការស្លាប់ក្នុងរយៈពេល១២ខែកន្លងមកតាមភេទ



ក្រាហ្វិក១៩ បានបង្ហាញថា៖ នៅ **ខេត្តក្រចេះ** ចំនួនអ្នកស្លាប់សរុបមាន ១.៤៣៧ នាក់ ក្នុងនោះមានប្រុស ៥៦.៧% និងស្រី ៤៣.៣% **ខេត្តមណ្ឌលគិរី** ចំនួនអ្នកស្លាប់សរុបមាន ២៣០ នាក់ ក្នុងនោះមានប្រុស ៥៦.១% និងស្រី ៤៣.៩% **ខេត្តព្រះវិហារ** ចំនួនអ្នកស្លាប់សរុបមាន ៦៥២ នាក់ ក្នុងនោះមានប្រុស ៥៩.៥% និងស្រី ៤០.៥% **ខេត្តរតនៈគិរី** ចំនួនអ្នកស្លាប់សរុបមាន ៥៥៥ នាក់ ក្នុងនោះមានប្រុស ៥៣% និងស្រី ៤៧% និង**ខេត្តស្ទឹងត្រែង** ចំនួនអ្នកស្លាប់សរុបមាន ៣៨៥ នាក់ ក្នុងនោះមានប្រុស ៥៦.១% និងស្រី ៤៣.៩% ។

### ឃ. កុមារអាយុក្រោម៥ឆ្នាំស្លាប់រយៈពេល១២ខែកន្លងមក




ក្រាហ្វិក២០ បានបង្ហាញថា៖ នៅ **ខេត្តក្រចេះ** ចំនួនអ្នកស្លាប់សរុបមាន១.៤៣៧នាក់ ក្នុងនោះមានកុមារអាយុក្រោម៥ឆ្នាំ ២% **ខេត្តមណ្ឌលគិរី** ចំនួនអ្នកស្លាប់សរុបមាន ២៣០ នាក់ ក្នុងនោះមានកុមារអាយុក្រោម៥ឆ្នាំ ០.៥% **ខេត្តព្រះវិហារ** ចំនួនអ្នកស្លាប់សរុបមាន ៦៥២ នាក់ ក្នុងនោះមានកុមារអាយុក្រោម៥ឆ្នាំ ១.៣% **ខេត្តរតនៈគិរី** ចំនួនអ្នកស្លាប់សរុបមាន ៥៥៥ នាក់ ក្នុងនោះមានកុមារអាយុក្រោម៥ឆ្នាំ ១.៤% និង**ខេត្តស្ទឹងត្រែង** ចំនួនអ្នកស្លាប់សរុបមាន ៣៨៥ នាក់ ក្នុងនោះមានកុមារអាយុក្រោម៥ឆ្នាំ ០.៩%។

# ២.៣ ប្រជាជនពិការ

## ២.៣.១ ពិការភាពនៃបុគ្គល

តារាង៦: ពិការភាពនៃបុគ្គលតាមខេត្តទាំង៥

| បរិយាយ | ក្រចេះ | មណ្ឌលគិរី | ព្រះវិហារ | រតនគិរី | ស្ទឹងត្រែង |
|---|---|---|---|---|---|
| បុគ្គលដែលរងគ្រោះដោយសារគ្រាប់មីន | 1,796 | 660 | 869 | 1,665 | 723 |
| មនុស្សចាស់ដែលគ្មានអ្នកមើលថែ | 139 | 68 | 337 | 44 | 52 |
| អនីតិជនដែលពិការ (អាយុក្រោម១៨ឆ្នាំ) | 206 | 202 | 76 | 194 | 72 |
| បុគ្គលពិការដែលមានចំណូល | 401 | 173 | 216 | 475 | 164 |
| បុគ្គលពិការដែលគ្មានចំណូល | 421 | 44 | 52 | 583 | 232 |

### ក. ការរងគ្រោះដោយសារគ្រាប់មីន



ក្រាហ្វិក២១: ភាគរយបុគ្គលដែលរងគ្រោះដោយសារគ្រាប់មីនតាមភេទ និងតាមខេត្ត

តារាង៦ និងក្រាហ្វិក២១ បានបង្ហាញថា៖ **ខេត្តក្រចេះ** អ្នករងគ្រោះដោយសារគ្រាប់មីនសរុបចំនួន ១.៧៩៦ នាក់ ក្នុងនោះប្រុស ៧៨.៤% និងស្រី ២១.៦% **ខេត្តមណ្ឌលគិរី** អ្នករងគ្រោះដោយសារគ្រាប់មីនសរុបចំនួន ៦៦០ នាក់ ក្នុងនោះប្រុស ៨៨.២% និងស្រី ១១.៨% **ខេត្តព្រះវិហារ** អ្នករងគ្រោះដោយសារគ្រាប់មីនសរុបចំនួន ៨៦៩ នាក់ ក្នុងនោះប្រុស ៨៩% និងស្រី ១១% **ខេត្តរតនៈគិរី** អ្នករងគ្រោះដោយសារគ្រាប់មីនសរុបចំនួន ១.៦៦៥ នាក់ ក្នុងនោះប្រុស ៧៩.៥% និងស្រី ២០.៥% និង**ខេត្តស្ទឹងត្រែង** អ្នករងគ្រោះដោយសារគ្រាប់មីនសរុបចំនួន ៧២៣នាក់ ក្នុងនោះប្រុស ៨៦.៥% និងស្រី ១៣.៥%។ ក្នុងចំណោមខេត្តទាំង៥ **ខេត្តក្រចេះ** មានអ្នករងគ្រោះដោយសារគ្រាប់មីនសរុបច្រើនជាងគេរហូតទៅដល់ **១.៧៩៦ នាក់** ។

## ខ. មនុស្សចាស់ដែលគ្មានអ្នកមើលថៃ ឬគ្រួសារផ្គត់ផ្គង់




តារាង៦ និងក្រាហ្វិក២២ បានបង្ហាញថាៈ **ខេត្តក្រចេះ** មនុស្សចាស់ដែលគ្មានអ្នកមើលថៃ ឬគ្រួសារផ្គត់ផ្គង់សរុបចំនួន ១៣៩ នាក់ ក្នុងនោះមានប្រុស ៣០.១% និងស្រី ៦៩.៩% **ខេត្តមណ្ឌលគិរី** មនុស្សចាស់ដែលគ្មានអ្នកមើលថៃ ឬគ្រួសារផ្គត់ផ្គង់សរុបចំនួន ៦៨ នាក់ ក្នុងនោះមានប្រុស ៣២.២% និងស្រី ៦៧.៨% **ខេត្តព្រះវិហារ** មនុស្សចាស់ដែលគ្មានអ្នកមើលថៃ ឬគ្រួសារផ្គត់ផ្គង់សរុបចំនួន ៣៣៧ នាក់ ក្នុងនោះមានប្រុស ១៨.៤%និងស្រី ៨១.៦% **ខេត្តរតនៈគិរី** មានមនុស្សចាស់ដែលគ្មានអ្នកមើលថៃ ឬគ្រួសារផ្គត់ផ្គង់មានសរុបចំនួន ៤៤ នាក់ ក្នុងនោះមានប្រុស ៤៣.៣% និងស្រី ៥៦.៧% និង**ខេត្តស្ទឹងត្រែង** មនុស្សចាស់ដែលគ្មានអ្នកមើលថៃ ឬគ្រួសារផ្គត់ផ្គង់សរុបចំនួន ៥២ នាក់ ក្នុងនោះមានប្រុស ៣១.៩% និងស្រី ៦៨.១% ។

## គ. អនីតិជនដែលពិការ (អាយុក្រោម១៨ឆ្នាំ)

ក្រាហ្វិក២៣: ភាគរយអនីតិជនដែលពិការ (អាយុក្រោម១៨ឆ្នាំ) តាមខេត្តទាំង៥




តារាង៦ និងក្រាហ្វិក២៣ បានបង្ហាញថា៖ **ខេត្តក្រចេះ** អនីតិជនដែលពិការ(អាយុក្រោម១៨ឆ្នាំ) សរុបចំនួន ២០៦ នាក់ ក្នុងនោះមានប្រុស ៥៣.៤% និងស្រី ៤៦.៦% **ខេត្តមណ្ឌលគិរី** អនីតិជនដែលពិការ(អាយុក្រោម១៨ឆ្នាំ) សរុបចំនួន ២០២ នាក់ ក្នុងនោះមានប្រុស ៥៨.៤% និងស្រី ៤១.៦% **ខេត្តព្រះវិហារ** អនីតិជនដែលពិការ(អាយុក្រោម១៨ឆ្នាំ) សរុបចំនួន ៧៦ នាក់ ក្នុងនោះមានប្រុស ៥៦% និងស្រី ៤៤% **ខេត្តរតនៈគិរី** អនីតិជនដែលពិការ(អាយុក្រោម១៨ឆ្នាំ) សរុបចំនួន ១៩៤ នាក់ ក្នុងនោះមានប្រុស ៦២.១% និងស្រី ៣៧.៩% និង**ខេត្តស្ទឹងត្រែង** អនីតិជនដែលពិការ(អាយុក្រោម១៨ឆ្នាំ) សរុបចំនួន ៧២ នាក់ ក្នុងនោះមានប្រុស ៥៧.៣% និងស្រី ៤២.៧%។

## ឃ. ប្រភពចំណូលជនពិការ

ក្រាហ្វិក២៤: ភាគរយប្រភពចំណូលរបស់ជនពិការតាមខេត្តទាំង៥



តារាង៦ និងក្រាហ្វិក២៤ បានបង្ហាញថា៖ **ខេត្តក្រចេះ** មានជនពិការសរុបចំនួន ៨២២ នាក់ ក្នុងនោះមានចំណូល ៤០.១% និងគ្មានចំណូល ៥៩.៩% **ខេត្តមណ្ឌលគិរី** មានជនពិការសរុបចំនួន ២១៧ នាក់ ក្នុងនោះមានចំណូល ២០.៣% និងគ្មានចំណូល ៧៩.៧% **ខេត្តព្រះវិហារ** មានជនពិការសរុបចំនួន ២៦៨ នាក់ ក្នុងនោះមានចំណូល ២១.៧%និងគ្មានចំណូល ៧៨.៣% **ខេត្តរតនៈគិរី** មានចំនួនជនពិការសរុបចំនួន ១.០៥៨ នាក់ ក្នុងនោះមានចំណូល ៦១.២% និងគ្មានចំណូល ៣៨.៨% និង**ខេត្តស្ទឹងត្រែង** មានជនពិការសរុបចំនួន ៣៩៦ នាក់ ក្នុងនោះមានចំណូល ៥៣.៣% និងគ្មានចំណូល ៤៦.៧%។

### ង. ផ្ទៃដីដែលបានសំអាតគ្រាប់មីន(គិតជាហិកតា)




ក្រាហ្វិក២៥ បានបង្ហាញថា៖ **ខេត្តក្រចេះ** ផ្ទៃដីដែលបានសំអាតគ្រាប់មីនសរុបចំនួន ១៣.៥៦៥ ហិកតា **ខេត្តមណ្ឌលគិរី** ផ្ទៃដីដែលបានសំអាតគ្រាប់មីនសរុបចំនួន ៦.៣៦៣ ហិកតា **ខេត្តព្រះវិហារ** ផ្ទៃដីដែលបានសំអាតគ្រាប់មីនសរុបចំនួន ៧.២៦៤ ហិកតា និង**ខេត្តស្ទឹងត្រែង** ផ្ទៃដីដែលបានសំអាតគ្រាប់មីនសរុបចំនួន ១៣៣ ហិកតា ។ ដោយឡែកនៅ **ខេត្តរតនៈគិរី** គ្មានផ្ទៃដីដែលបានសំអាតគ្រាប់មីនទេ។

## ២.៤ ការប្រើប្រាស់ទឹក និង អនាម័យ

តារាង៧: ប្រភពនៃការប្រើប្រាស់ទឹកសម្រាប់គ្រួសារ

| បរិយាយ | ក្រចេះ | មណ្ឌលគិរី | ព្រះវិហារ | រតនៈគិរី | ស្ទឹងត្រែង |
|---|---|---|---|---|---|
| គ្រួសារដែលទទួលបានទឹកស្អាតបរិភោគ (ទុយោ) | 34,338 | 3,228 | 8,839 | 7,386 | 4,415 |
| គ្រួសារដែលមានអណ្តូង | 20,449 | 9,665 | 28,080 | 28,106 | 8,364 |
| គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ | 8,132 | 808 | 1,538 | 327 | 2,868 |
| គ្រួសារបានប្រើប្រាស់ទឹកស្រះ /បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ | 19,554 | 5,447 | 5,628 | 10,282 | 16,379 |
| គ្រួសារមានបង្គន់អនាម័យផ្ទាល់ខ្លួន | 40,322 | 8,990 | 21,869 | 15,638 | 14,505 |
| **ចំនួនគ្រួសារសរុប** | 122,795 | 28,138 | 65,954 | 61,739 | 46,531 |

ក. ការប្រើប្រាស់ទឹករបស់គ្រួសារ




តារាង៧ និងក្រាហ្វិក២៦ បានបង្ហាញថា៖ **ខេត្តក្រចេះ** មានគ្រួសារសរុបចំនួន ១២២.៧៩៥ គ្រួសារ ហើយគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ (ទុយោ)ចំនួន ៤១.៦% គ្រួសារដែលប្រើប្រាស់ទឹកអណ្តូងចំនួន ២៤.៨% គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគចំនួន ៩.៩% និងគ្រួសារប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគចំនួន ២៣.៧ % **ខេត្តមណ្ឌលគិរី** មានគ្រួសារសរុបចំនួន ២៨.១៣៨ គ្រួសារ ហើយគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ (ទុយោ)ចំនួន ១៦.៩% គ្រួសារដែលប្រើប្រាស់ទឹកអណ្តូងចំនួន ៥០.៥% គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគចំនួន ៤.២% និងគ្រួសារប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ២៨.៤% **ខេត្តព្រះវិហារ** មានគ្រួសារសរុប

ចំនួន ៦៥.៩៥៤ គ្រួសារ ហើយគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ (ទុយោ)ចំនួន ២០% គ្រួសារដែលប្រើប្រាស់ទឹកអណ្តូងចំនួន ៦៣.៧% គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគចំនួន ៣.៥% និងគ្រួសារប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ១២.៨% **ខេត្តរតនៈគិរី** មានគ្រួសារសរុបចំនួន ៦១.៧៣៩ គ្រួសារ ហើយគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ (ទុយោ)ចំនួន ១៦% គ្រួសារដែលប្រើប្រាស់ទឹកអណ្តូងចំនួន ៦១% គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគចំនួន ០.៧ % និងគ្រួសារប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ២២.៣% និង**ខេត្តស្ទឹងត្រែង** មានគ្រួសារសរុបចំនួន ៤៦.៥៣១ គ្រួសារ ហើយគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ (ទុយោ)ចំនួន ១៣.៨% គ្រួសារដែលប្រើប្រាស់ទឹកអណ្តូងចំនួន ២៦.១% គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគចំនួន ៩% និងគ្រួសារប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ៥១.១% ។

ខ. អនាម័យ




ក្រាហ្វិក២៧ បានបង្ហាញថា៖ **ខេត្តក្រចេះ** មានគ្រួសារសរុប ៨៥.៩១៣ គ្រួសារ ហើយគ្រួសារដែលមានបង្គន់អនាម័យសម្រាប់ប្រើប្រាស់ស្មើនឹង ៣២.៨% **ខេត្តមណ្ឌលគិរី** មានគ្រួសារសរុប ២០.២៧៣ គ្រួសារ ហើយគ្រួសារដែលមានបង្គន់អនាម័យសម្រាប់ប្រើប្រាស់ស្មើនឹង ៣១.៩% **ខេត្តព្រះវិហារ** មានគ្រួសារសរុប ៥៨.៧១៨ គ្រួសារ ហើយគ្រួសារដែលមានបង្គន់អនាម័យសម្រាប់ប្រើប្រាស់ស្មើនឹង ៣៣.២% **ខេត្តរតនៈគិរី** មានគ្រួសារសរុប ៤៩.៨៧២ គ្រួសារ ហើយគ្រួសារដែលមានបង្គន់អនាម័យសម្រាប់ប្រើប្រាស់ស្មើនឹង ២៥.៣% និង**ខេត្តស្ទឹងត្រែង** មានគ្រួសារសរុប ៣៥.៧៨៣ គ្រួសារ ហើយគ្រួសារដែលមានបង្គន់អនាម័យសម្រាប់ប្រើប្រាស់ស្មើនឹង ៣១.២ % ។

## គ. គ្រួសារដែលគ្មានផ្ទះសម្បែង




ក្រាហ្វិក២៨ បានបង្ហាញថា៖ **ខេត្តក្រចេះ** ក្នុងចំណោមគ្រួសារសរុប ៨៥.៩១៣ គ្រួសារ មានគ្រួសារដែលរស់នៅលើដីសាធារណៈ ១.៦% និងគ្រួសារដែលគ្មានផ្ទះសម្បែង ០.៧% **ខេត្តមណ្ឌលគិរី** ក្នុងចំណោមគ្រួសារសរុប ២០.២៧៣ គ្រួសារ មានគ្រួសារដែលរស់នៅលើដីសាធារណៈ ០.២% និងគ្រួសារដែលគ្មានផ្ទះសម្បែង ០.២% **ខេត្តព្រះវិហារ** ក្នុងចំណោមគ្រួសារសរុប ៥៨.៧១៨ គ្រួសារ មានគ្រួសារដែលរស់នៅលើដីសាធារណៈ ០.២ % និងគ្រួសារដែលគ្មានផ្ទះសម្បែង ០.១ % **ខេត្តរតនៈគិរី** ក្នុងចំណោមគ្រួសារសរុប ៤៩.៨៧២ គ្រួសារ មានគ្រួសារដែលរស់នៅលើដីសាធារណៈ ០.៤% និងមិនមានគ្រួសារដែលគ្មានផ្ទះសម្បែងទេ និង**ខេត្តស្ទឹងត្រែង** ក្នុងចំណោមគ្រួសារសរុប ៣៥.៧៨៣ គ្រួសារ មានគ្រួសារដែលរស់នៅលើដីសាធារណៈ ០.៤% និងគ្រួសារដែលគ្មានផ្ទះសម្បែង ០.៥ %។

## ២.៥ បរិស្ថាន និងធនធានធម្មជាតិ

ក. ទីតាំងរបស់ផ្ទៃដីចោលសំរាម




ក្រាហ្វិក២៩ បានបង្ហាញថា៖ **ខេត្តក្រចេះ** មានផ្ទៃដីចោលសំរាមចំនួន ៩៧ ហិកតា **ខេត្តព្រះវិហារ** មានផ្ទៃដីចោលសំរាមចំនួន ៣ហិកតា **ខេត្តស្ទឹងត្រែង** មានផ្ទៃដីចោលសំរាមចំនួន ១១ ហិកតា ។

ខ. ទីតាំងរបស់ផ្ទៃដីចោលកាកសំណល់ឧស្សាហកម្ម



ក្រាហ្វិក៣០ បានបង្ហាញថាៈ ក្នុងចំណោមខេត្តទាំង៥ មានតែ **ខេត្តក្រចេះ** ទេដែលមានផ្ទៃដីចោលកាកសំណល់ឧស្សាហកម្មចំនួន ១ ហិកតា ។

គ. ទីតាំងរោងចក្រ




ក្រាហ្វិក៣១ បានបង្ហាញពីក្រលាផ្ទៃ ដីទីតាំងរោងចក្រ ក្នុងនោះ **ខេត្តព្រះវិហារ** មានចំនួន ១០ហិកតា ។

ឃ. ការចម្អិនអាហាររបស់គ្រួសារ



ក្រាហ្វិក៣២ បានបង្ហាញថា៖ **ខេត្តក្រចេះ** ក្នុងចំណោមគ្រួសារសរុប ៨៥.៩១៣ គ្រួសារ មានគ្រួសារដែលប្រើប្រាស់អុស/ធ្យូងស្មើនឹង ៧៤.៥% **ខេត្តមណ្ឌលគិរី** ក្នុងចំណោមគ្រួសារសរុប ២០.២៧៣ គ្រួសារ មានគ្រួសារដែលប្រើប្រាស់អុស/ធ្យូងស្មើនឹង ៦៩.៧% **ខេត្តព្រះវិហារ** ក្នុងចំណោមគ្រួសារសរុប ៥៨.៧១៨ គ្រួសារ មានគ្រួសារដែលប្រើប្រាស់អុស/ធ្យូងស្មើនឹង៨៣.៧% **ខេត្តរតនៈគិរី** ក្នុងចំណោមគ្រួសារសរុប ៤៩.៨៧២ គ្រួសារ មានគ្រួសារដែលប្រើប្រាស់អុស/ធ្យូងស្មើនឹង ៦៣.៥% និង**ខេត្តស្ទឹងត្រែង** ក្នុងចំណោមមេគ្រួសារសរុប ៣៥.៧៨៣ គ្រួសារ មានគ្រួសារដែលប្រើប្រាស់អុស/ធ្យូងស្មើនឹង ៦១ % ។

ង. ធនធានធម្មជាតិ

តារាង៨: ធនធានធម្មជាតិ

| **បរិយាយ** | **ក្រចេះ** | **មណ្ឌលគិរី** | **ព្រះវិហារ** | **រតនគិរី** | **ស្ទឹងត្រែង** |
|---|---|---|---|---|---|
| ព្រៃឈើគ្របដណ្តប់ | 13,298 | 22,390 | 25,408 | 120 | 26,097 |
| ការដាំកូនឈើ | 16 | 16 | 28 | 0 | 24 |
| ការកាប់ឆ្ការព្រៃ | 421 | 188 | 2943 | 0 | 9107 |

តារាង៨ បានបង្ហាញថា៖ **ខេត្តក្រចេះ** មានព្រៃឈើគ្របដណ្តប់ចំនួន ១៣.២៩៨ ហិកតា ការដាំកូនឈើមានចំនួន ១៦ ហិកតា និងការកាប់ឆ្ការព្រៃមានចំនួន ៤២១ ហិកតា **ខេត្តមណ្ឌលគិរី** មានព្រៃឈើគ្របដណ្តប់ចំនួន ២២.៣៩០ ហិកតា ការដាំកូនឈើមានចំនួន ១៦ ហិកតា និងការកាប់ឆ្ការព្រៃមានចំនួន ១៨៨ ហិកតា **ខេត្តព្រះវិហារ** មានព្រៃឈើគ្របដណ្តប់ចំនួន ២៥.៤០៨ ហិកតា ការដាំកូនឈើមានចំនួន ២៨ ហិកតា និងការកាប់ឆ្ការព្រៃមានចំនួន ២៨ ហិកតា **ខេត្តរតនៈគិរី** មានព្រៃឈើគ្របដណ្តប់ចំនួន ១២០ ហិកតា និង**ខេត្តស្ទឹងត្រែង** មានព្រៃឈើគ្របដណ្តប់ចំនួន ២៦.០៩៧ ហិកតា ការដាំកូនឈើមានចំនួន ២៤ ហិកតា និងការកាប់ឆ្ការព្រៃមានចំនួន ៩.១០៧ ហិកតា ។ ទិន្នន័យដូចបានរៀបរាប់ខាងលើបញ្ជាក់អោយឃើញថា៖ ការដាំកូនឈើឡើងវិញមានទំហំផ្ទៃដីតិចតួចជាងការកាប់ឆ្ការព្រៃ។

## ២.៦ គ្រោះធម្មជាតិ

ក. គ្រួសារដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ

តារាង៩: ចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់ដោយសារគ្រោះធម្មជាតិតាមខេត្តទាំង៥

| គ្រោះធម្មជាតិ | ទឹកជំនន់ | ដីបាក់ឬស្រុត | គ្រោះរាំងស្ងួត | ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ |
|---|---|---|---|---|
| ក្រចេះ | 3,827 | 261 | 5,013 | 203 |
| មណ្ឌលគីរី | - | - | 639 | 20 |
| ព្រះវិហារ | 138 | - | 7,501 | 580 |
| រតនៈគីរី | 454 | 80 | 212 | 260 |
| ស្ទឹងត្រែង | 3,326 | 46 | 982 | 25 |

តារាង៩ បានបង្ហាញពី ចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់ដោយសារគ្រោះធម្មជាតិ ក្នុងខេត្តទាំង៥៖ **ខេត្តក្រចេះ** រងគ្រោះដោយទឹកជំនន់មានចំនួន ៣.៨២៧ គ្រួសារ ដីបាក់ឬស្រុតមានចំនួន ២៦១ គ្រួសារ គ្រោះរាំងស្ងួតមានចំនួន ៥.០១៣ គ្រួសារ និងជួបខ្យល់ព្យុះ/ខ្យល់កន្ត្រាក់មានចំនួន ២០៣ គ្រួសារ **ខេត្តមណ្ឌលគិរី** គ្រួសារដែលទទួលរងផលប៉ះពាល់ដោយសារគ្រោះរាំងស្ងួតមានចំនួន ៦៣៩ គ្រួសារ និងជួបខ្យល់ព្យុះ/ខ្យល់កន្ត្រាក់មានចំនួន ២០ គ្រួសារ **ខេត្តព្រះវិហារ** រងគ្រោះដោយទឹកជំនន់មានចំនួន ១៣៨ គ្រួសារ គ្រោះរាំងស្ងួតមានចំនួន ៧.៥០១ គ្រួសារ និងជួបខ្យល់ព្យុះ/ខ្យល់កន្ត្រាក់មានចំនួន ៥៨០ គ្រួសារ **ខេត្តរតនៈគិរី** រងគ្រោះទឹកជំនន់មានចំនួន ៤៥៤ គ្រួសារ ដីបាក់ឬស្រុតមានចំនួន ៨០ គ្រួសារ គ្រោះរាំងស្ងួតមានចំនួន ២១២ គ្រួសារ និងជួបខ្យល់ព្យុះ/ខ្យល់កន្ត្រាក់មានចំនួន ២៦០ គ្រួសារ និង**ខេត្តស្ទឹងត្រែង** រងគ្រោះដោយទឹកជំនន់មានចំនួន ៣.៣២៦ គ្រួសារ ដីបាក់ឬស្រុតមានចំនួន ៤៦ គ្រួសារ គ្រោះរាំងស្ងួតមានចំនួន ៩៨២ គ្រួសារ និងជួបខ្យល់ព្យុះ/ខ្យល់កន្ត្រាក់មានចំនួន ២៥ គ្រួសារ ។

ខ. ផ្ទៃដីដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ

តារាង១០: ផ្ទៃដីដែលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិតាមខេត្តទាំង៥ (គិតជាហិកតា)

| គ្រោះធម្មជាតិ | ទឹកជំនន់ | ដីបាក់ឬស្រុត | គ្រោះរាំងស្ងួត | ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ |
|---|---|---|---|---|
| ក្រចេះ | 2,792 | 3,546 | 5,132 | 120 |
| មណ្ឌលគីរី | - | - | 583 | 14 |
| ព្រះវិហារ | 230 | - | 10,710 | 472 |
| រតនៈគីរី | 448 | 48 | 43 | 29 |
| ស្ទឹងត្រែង | 2,219 | 111 | 794 | 111 |

តារាង១០ បានបង្ហាញពី ផ្ទៃដីដែលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិក្នុងខេត្តទាំង៥៖ **ខេត្តក្រចេះ** រងគ្រោះដោយទឹកជំនន់មានចំនួន ២.៧៩២ ហិកតា ដីបាក់ឬស្រុតមានចំនួន ៣.៥៤៦ ហិកតា ជួបគ្រោះរាំងស្ងួតមានចំនួន ៥.១៣២ ហិកតា និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់មានចំនួន ១២០ ហិកតា **ខេត្តមណ្ឌលគីរី** ជួបគ្រោះរាំងស្ងួតមានចំនួន ៥៨៣ ហិកតា និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់មានចំនួន ១៤ ហិកតា **ខេត្តព្រះវិហារ** រងគ្រោះដោយទឹកជំនន់មានចំនួន ២៣០ ហិកតា គ្រោះរាំងស្ងួតមានចំនួន ១០.៧១០ ហិកតា និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់មានចំនួន ៤៧២ ហិកតា **ខេត្តរតនៈគីរី** រងគ្រោះដោយទឹកជំនន់មានចំនួន ៤៤៨ ហិកតា ដីបាក់ឬស្រុតមានចំនួន ៤៨ ហិកតា គ្រោះរាំងស្ងួតមានចំនួន ៤៣ ហិកតា និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់មានចំនួន ២៩ ហិកតា និង **ខេត្តស្ទឹងត្រែង** រងគ្រោះដោយទឹកជំនន់មានចំនួន ២.២១៩ ហិកតា ដីបាក់ឬស្រុតមានចំនួន ១១១ ហិកតា គ្រោះរាំងស្ងួតមានចំនួន ៧៩៤ ហិកតា និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់មានចំនួន ១១១ ហិកតា ។

## ២.៧ សន្តិសុខសង្គម និង សេដ្ឋកិច្ច

### ២.៧.១ អសន្តិសុខសង្គម

បញ្ហាសន្តិសុខសង្គម គឺសំដៅទៅលើករណីលួច ឆក់ ប្លន់ ចាប់ជំរិត និងឧក្រិដ្ឋកម្ម ប្រើប្រាស់គ្រឿងញៀន ជម្លោះដីធ្លីនៅក្នុងមូលដ្ឋាន។ ចំពោះករណីទាំងអស់នេះទោះបីជាមានចំនួនកើតឡើងច្រើនករណី តែរាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរក្នុងមូលដ្ឋានខិតខំដោះស្រាយបានមួយចំនួនធំដែរ ដូច្នេះតួលេខគ្រាន់តែបង្ហាញនូវករណីដែលបានដោះស្រាយ និងមិនបានដោះស្រាយតែប៉ុណ្ណោះ។

## ក. ករណីលួចឆក់




ក្រាហ្វិក៣៣ បានបង្ហាញថា៖ **ខេត្តក្រចេះ** មានករណីលួចកើតឡើងសរុបចំនួន ៣៩៥ ករណី ក្នុងនោះ បានធ្វើការដោះស្រាយបានចំនួន ១២៦ ករណី **ខេត្តមណ្ឌលគិរី** មានករណីលួចកើតឡើងសរុបចំនួន ៧១ ករណី ក្នុងនោះបានធ្វើការដោះស្រាយបានចំនួន ២៦ ករណី **ខេត្តព្រះវិហារ** មានករណីលួចកើតឡើងសរុបចំនួន ៨៩ ករណី ក្នុងនោះ បានធ្វើការដោះស្រាយបានចំនួន ៥៣ ករណី **ខេត្តរតនៈគិរី** មានករណីលួចកើតឡើងសរុបចំនួន ២៧២ ករណី ក្នុងនោះ បានធ្វើការដោះស្រាយបានចំនួន ២០២ ករណី និង**ខេត្តស្ទឹងត្រែង** មានករណីលួចកើតឡើងសរុបចំនួន ៨០ ករណី ក្នុងនោះ បានធ្វើការដោះស្រាយបានចំនួន ៤៩ ករណី ។

ខ. ករណីឃាតកម្ម ប្លន់ និងឧក្រិដ្ឋកម្ម




ក្រាហ្វិក៣៤ បានបង្ហាញថា៖ **ខេត្តក្រចេះ** ករណីឃាតកម្ម ប្លន់ និងឧក្រិដ្ឋកម្ម បានកើតឡើងសរុប ៦ ករណី បានដោះស្រាយ ៥ ករណី **ខេត្តមណ្ឌលគិរី** ករណីឃាតកម្ម ប្លន់ និងឧក្រិដ្ឋកម្ម បានកើតឡើងសរុប ៣ ករណី តែមិនទាន់បានដោះស្រាយ **ខេត្តព្រះវិហារ** ករណីឃាតកម្ម ប្លន់ និងឧក្រិដ្ឋកម្ម បានកើតឡើងសរុប ៤ ករណី បានដោះស្រាយ ២ ករណី **ខេត្តរតនៈគិរី** ករណីឃាតកម្ម ប្លន់ និងឧក្រិដ្ឋកម្ម បានកើតឡើងសរុប ៥៦ ករណី បានដោះស្រាយ ៥៦ ករណី និង**ខេត្តស្ទឹងត្រែង** ករណី ឃាតកម្ម ប្លន់ និងឧក្រិដ្ឋកម្ម បានកើតឡើងសរុប ១៦ ករណី បានដោះស្រាយ ៥ ករណី

គ. ជម្លោះដីធ្លី



ក្រាហ្វិក៣៥ បានបង្ហាញថាៈ បញ្ហាជម្លោះដីធ្លីដែលបានកើតឡើងក្នុង **ខេត្តក្រចេះ** សរុបមានចំនួន ៥៤០ ករណី ក្នុងនោះអាជ្ញាធរមូលដ្ឋានបានធ្វើការដោះស្រាយជូនប្រជាពលរដ្ឋបានចំនួន ៤៤៦ ករណី **ខេត្តមណ្ឌលគិរី** មានបញ្ហាជម្លោះដីធ្លីដែលបានកើតឡើងសរុបចំនួន ១៦៩ ករណី ក្នុងនោះដោះស្រាយបានចំនួន ១១១ ករណី **ខេត្តព្រះវិហារ** មានបញ្ហាជម្លោះដីធ្លីដែលបានកើតឡើងសរុប ៤៦៧ ករណី និងបានដោះស្រាយ ៣៧៨ ករណី **ខេត្តរតនៈគិរី** មានបញ្ហាជម្លោះដីធ្លីដែលបានកើតឡើងសរុបចំនួន ៦៣២ ករណី និងបានធ្វើការដោះស្រាយបានចំនួន ៥៧៦ ករណី និង**ខេត្តស្ទឹងត្រែង** មានបញ្ហាជម្លោះដីធ្លីដែលបានកើតឡើងសរុបចំនួន ២២៩ ករណី និងធ្វើការដោះស្រាយបានចំនួន ១៦៩ ករណី។ កត់សម្គាល់ឃើញថា **ខេត្តរតនៈគិរី** កើតមានបញ្ហាជម្លោះដីធ្លីបានកើតឡើងច្រើនករណីជាងគេ ក្នុងបណ្តាលខេត្តទាំង៥ ។

ឃ. ការទាស់ទែងគ្នារបស់ប្រជាពលរដ្ឋ




ក្រាហ្វិក៣៦ បានបង្ហាញថា៖ **ខេត្តក្រចេះ** មានចំនួនករណីនៃការទាស់ទែងគ្នារបស់ប្រជាពលរដ្ឋកើតឡើងសរុបចំនួន ៦៦៧ ករណី ដោះស្រាយបាន ៥៤៤ ករណី **ខេត្តមណ្ឌលគិរី** មានចំនួនករណីនៃការទាស់ទែងគ្នារបស់ប្រជាពលរដ្ឋកើតឡើងសរុបចំនួន១៤៧ ករណី ដោះស្រាយបាន ១៣៣ករណី **ខេត្តព្រះវិហារ** មានចំនួនករណីនៃការទាស់ទែងគ្នារបស់ប្រជាពលរដ្ឋកើតឡើងសរុបចំនួន ៣០៤ករណី ដោះស្រាយបាន ២១៩ ករណី **ខេត្តរតនៈគិរី** មានចំនួនករណីនៃការទាស់ទែងគ្នារបស់ប្រជាពលរដ្ឋ

កើតឡើងសរុបចំនួន ៥៦៥ ករណី ដោះស្រាយបាន ៥៣៤ ករណី និង**ខេត្តស្ទឹងត្រែង** មានចំនួនករណីនៃការទាស់ទែងគ្នារបស់ប្រជាពលរដ្ឋកើតឡើងសរុបចំនួន ២៥១ ករណី ដោះស្រាយបាន ២០៦ ករណី ។

### ង. អំពើហិង្សាក្នុងគ្រួសារ និងគ្រឿងញៀន




ក្រាហ្វិក៣៧ បានបង្ហាញពីគ្រួសារប្រើអំពើហិង្សា និងគ្រឿងញៀ៖ **ខេត្តក្រចេះ** មានគ្រួសារសរុបចំនួន ៨៥.៩១៣ គ្រួសារ ក្នុងនោះមាន ០.៨ % គ្រួសារ បានប្រើអំពើហិង្សាក្នុងគ្រួសារ និង ០.២% គ្រួសារ ទៀតបានប្រើប្រាស់គ្រឿងញៀន **ខេត្តមណ្ឌលគិរី** មានគ្រួសារសរុបចំនួន ២០.២៧៣ គ្រួសារ ក្នុងនោះមាន ១.0% គ្រួសារ បានប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ និង ០.២% គ្រួសារ ទៀតបានប្រើប្រាស់គ្រឿងញៀន **ខេត្តព្រះវិហារ** មានគ្រួសារសរុបចំនួន ៥៨.៧១៨ គ្រួសារ ក្នុងនោះមាន ១.១% គ្រួសារ បានប្រើអំពើហិង្សាក្នុងគ្រួសារ និង ០.១% គ្រួសារ ទៀតបានប្រើប្រាស់គ្រឿងញៀន **ខេត្តរតនៈគិរី** មានគ្រួសារសរុបចំនួន ៤៩.៨៧២ គ្រួសារ ក្នុងនោះមាន ០.៩% គ្រួសារ បានប្រើអំពើហិង្សាក្នុងគ្រួសារ និង ០.២% គ្រួសារ ទៀតបានប្រើប្រាស់គ្រឿងញៀន និង**ខេត្តស្ទឹងត្រែង** មានគ្រួសារសរុបចំនួន ៣៥.៧៨៣ គ្រួសារ ក្នុងនោះមាន ១.៨% បានប្រើអំពើហិង្សាក្នុងគ្រួសារ និងមិនមានករណីប្រើប្រាស់គ្រឿងញៀន។

ច. បទឃាតកម្ម




ក្រាហ្វិក៣៨ បានបង្ហាញថា៖ **ខេត្តក្រចេះ** មានបទឃាតកម្មបានកើតឡើងចំនួន ៤ ករណី និងធ្វើការដោះស្រាយបានចំនួន ៣ ករណី **ខេត្តមណ្ឌលគិរី** មានបទឃាតកម្មបានកើតឡើងចំនួន ៤ ករណី និងធ្វើការដោះស្រាយបានចំនួន ១ ករណី **ខេត្តព្រះវិហារ** មានបទឃាតកម្មបានកើតឡើងចំនួន ១ ករណី និងធ្វើការដោះស្រាយបានចំនួន ១ ករណី **ខេត្តរតនៈគិរី** មិនមានបទឃាតកម្មណាបានកើតឡើងនោះទេ និង**ខេត្តស្ទឹងត្រែង** មានបទឃាតកម្មបានកើតឡើងចំនួន ៥ ករណី និងធ្វើការដោះស្រាយបានចំនួន ២ ករណី ។

### ឆ. ចំនួនករណីស្ត្រីដែលបានរងគ្រោះដោយសារការចាប់រំលោភ និងការជួញដូរ




ក្រាហ្វិក៣៩ បានបង្ហាញថាៈ **ខេត្តក្រចេះ** មានស្ត្រីរងគ្រោះដោយសារចាប់រំលោភ ចំនួន ១៣ ករណី និងការជួញដូរចំនួន៤ ករណី **ខេត្តមណ្ឌលគិរី** មានស្ត្រីរងគ្រោះដោយសារចាប់រំលោភ ចំនួន ៤ ករណី និងគ្មានករណីជួញដូរទេ **ខេត្តព្រះវិហារ** មានស្ត្រីរងគ្រោះដោយសារចាប់រំលោភ ចំនួន ១៣ ករណី និងការជួញដូរចំនួន១ ករណី **ខេត្តរតនៈគិរី** មានស្ត្រីរងគ្រោះដោយសារចាប់រំលោភ ចំនួន ១៦ ករណី និងការជួញដូរចំនួន៤ ករណី និង**ខេត្តស្ទឹងត្រែង** មានស្ត្រីរងគ្រោះដោយសារចាប់រំលោភ ចំនួន ៨ ករណី និងការជួញដូរចំនួន១ ករណី ។

### ជ. ស្ត្រីរងគ្រោះដោយសារការចាប់រំលោភ និងការជួញដូរតាមក្រុមអាយុ



ក្រាហ្វិក៤០ បានបង្ហាញថាៈ **ខេត្តក្រចេះ** មានស្ត្រីរងគ្រោះដោយសារចាប់រំលោភនិងជួញដូរ ចំនួន ១៧ ករណី (ស្ត្រីរងគ្រោះដោយសារការចាប់រំលោភអាយុក្រោម១៨ឆ្នាំ ចំនួន ៩ ករណី) **ខេត្តមណ្ឌលគិរី** មានស្ត្រីរងគ្រោះដោយសារចាប់រំលោភនិងជួញដូរចំនួន ៤ ករណី (ស្ត្រីរងគ្រោះដោយសារការចាប់រំលោភអាយុក្រោម១៨ឆ្នាំ ចំនួន ៣ ករណី) **ខេត្តព្រះវិហារ** មានស្ត្រីរងគ្រោះដោយសារចាប់រំលោភនិងជួញដូរចំនួន ១៤ ករណី (ស្ត្រីរងគ្រោះដោយសារការចាប់រំលោភអាយុក្រោម១៨ឆ្នាំ ចំនួន ១០ ករណី និងមានការជួញដូរ១ករណី) **ខេត្តរតនៈគិរី** មានស្ត្រីរងគ្រោះដោយសារចាប់រំលោភនិងជួញដូរចំនួន ២០ ករណី (ស្ត្រីរងគ្រោះដោយសារការចាប់រំលោភអាយុក្រោម១៨ឆ្នាំ ចំនួន ១០ ករណី និងមានការជួញដូរ ១ ករណី) និង**ខេត្តស្ទឹងត្រែង** មានស្ត្រីរងគ្រោះដោយសារចាប់រំលោភនិងជួញដូរចំនួន ៩ ករណី (ស្ត្រីរងគ្រោះដោយសារការចាប់រំលោភអាយុក្រោម១៨ឆ្នាំ ចំនួន ៧ករណី) ។

២.៧.២. ស្ថានភាពសេដ្ឋកិច្ចគ្រួសារ




ក្រាហ្វិក៤១ បង្ហាញពីចំនួនគ្រួសារដែលធ្វើសកម្មភាពអាជីវកម្មចម្បង ក្រៅពីការធ្វើការងារកសិកម្ម៖ **ខេត្តក្រចេះ** មានចំនួន ៦.៧៧២ គ្រួសារ **ខេត្តមណ្ឌលគិរី** មានចំនួន ២.៣០៩ គ្រួសារ **ខេត្តព្រះវិហារ** មានចំនួន ៦.៣៨៤ គ្រួសារ **ខេត្តរតនៈគិរី** មានចំនួន ៥.២៥៩ គ្រួសារ និង**ខេត្តស្ទឹងត្រែង** មានចំនួន ៣.១៤០ គ្រួសារ។

### ក. ចំនួនគ្រួសារដែលមានម៉ាស៊ីនកិនស្រូវ




ក្រាហ្វិក៤២ បានបង្ហាញថា៖ សកម្មភាពអាជីវកម្មដោយប្រើម៉ាស៊ីនកិនស្រូវ **ខេត្តក្រចេះ** មានចំនួន ៨២៩ គ្រួសារ **ខេត្តមណ្ឌលគិរី** ចំនួន ៦១ គ្រួសារ **ខេត្តព្រះវិហារ** ចំនួន ៥៩៣ គ្រួសារ **ខេត្តរតនៈគិរី** ចំនួន ៩៧៣ គ្រួសារ និង**ខេត្តស្ទឹងត្រែង** ចំនួន ៣៩៥ គ្រួសារ។

### ខ. ផ្នែកសណ្ឋាគារ ផ្ទះសំណាក់និងភោជនីយដ្ឋាន




ក្រាហ្វិក៤៣ បង្ហាញពីសកម្មភាពអាជីវកម្មសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន៖ **ខេត្តក្រចេះ** មានចំនួន ៨១ គ្រួសារ **ខេត្តមណ្ឌលគិរី** មានចំនួន ៨៩ គ្រួសារ **ខេត្តព្រះវិហារ** មានចំនួន ១១៥ គ្រួសារ **ខេត្តរតនៈគិរី** មានចំនួន ៧៩ គ្រួសារ និង**ខេត្តស្ទឹងត្រែង** មានចំនួន ៦៦ គ្រួសារ។

### គ. អាជីវកម្មជួសជុលម៉ាស៊ីនគ្រប់ប្រភេទ




ក្រាហ្វិក៤៤ បង្ហាញពីសកម្មភាពអាជីវកម្មផ្នែកជួសជុលម៉ាស៊ីនគ្រប់ប្រភេទ៖ **ខេត្តក្រចេះ** មានចំនួន ១.២៨០ គ្រួសារ **ខេត្តមណ្ឌលគិរី** មានចំនួន ៣៦០ គ្រួសារ **ខេត្តព្រះវិហារ** មានចំនួន ៦៦៣ គ្រួសារ **ខេត្តរតនៈគិរី** មានចំនួន ៧២០ គ្រួសារ និង**ខេត្តស្ទឹងត្រែង** មានចំនួន ៣៧៣ គ្រួសារ ។

### ឃ. អាជីវកម្មគ្រឿងសំណង់ និងសង្ហារិម




ក្រាហ្វិក៤៥ បង្ហាញពីសកម្មភាពអាជីវកម្មរបស់គ្រួសារលក់គ្រឿងសំណង់ និងគ្រឿងសង្ហារិម៖ **ខេត្តក្រចេះ** មានចំនួន ៣២៣ គ្រួសារ **ខេត្តមណ្ឌលគិរី** មានចំនួន ១៤៧ គ្រួសារ **ខេត្តព្រះវិហារ** មានចំនួន ៣៨០ គ្រួសារ **ខេត្តរតនៈគិរី** មានចំនួន ២២៦ គ្រួសារ និង**ខេត្តស្ទឹងត្រែង** មានចំនួន ១៨៧ គ្រួសារ។

ង. គ្រួសារដែលមានលក់គ្រឿងទេស និងភេសជ្ជៈ លក់ថ្នាំពេទ្យ និងបើកគ្លីនិកឯកជន



ក្រាហ្វិក៤៦: ចំនួនគ្រួសារមានលក់គ្រឿងទេស និងភេសជ្ជៈ លក់ថ្នាំពេទ្យ និងបើកគ្លីនិកឯកជនតាមខេត្តទាំង៥

ក្រាហ្វិក៤៦ បង្ហាញពីសកម្មភាពអាជីវកម្មរបស់គ្រួសារដែលមានលក់គ្រឿងទេស និងភេសជ្ជៈ លក់ថ្នាំពេទ្យ និងបើកគ្លីនិកឯកជន៖ **ខេត្តក្រចេះ** មានចំនួន ១.២៩២ គ្រួសារ **ខេត្តមណ្ឌលគិរី** មានចំនួន ៤៩៩ គ្រួសារ **ខេត្តព្រះវិហារ** មានចំនួន ១.៨៥៤ គ្រួសារ **ខេត្តរតនៈគិរី** មានចំនួន ១.០៦៥ គ្រួសារ និង **ខេត្តស្ទឹងត្រែង** មានចំនួន ៥៣៨ គ្រួសារ ។

ច. គ្រួសារមានស្ថានីយចាក់ប្រេងឥន្ធនៈគ្រប់កម្រិត



ក្រាហ្វិក៤៧: ចំនួនគ្រួសារដែលមានស្ថានីយចាក់ប្រេងឥន្ធនៈគ្រប់កម្រិតតាមខេត្តទាំង៥

ក្រាហ្វិក៤៧ បង្ហាញពីសកម្មភាពអាជីវកម្មរបស់គ្រួសារដែលមានស្ថានីយចាក់ប្រេងឥន្ធនៈគ្រប់កម្រិត តាមខេត្តទាំង៥៖ **ខេត្តក្រចេះ** មានចំនួន ២.០៩៩ គ្រួសារ **ខេត្តមណ្ឌលគិរី** មានចំនួន ៤៧២ គ្រួសារ **ខេត្តព្រះវិហារ** មានចំនួន ១.៩៩២ គ្រួសារ **ខេត្តរតនៈគិរី** មានចំនួន ៣៦០ គ្រួសារ និង**ខេត្តស្ទឹងត្រែង** មានចំនួន ៧២០ គ្រួសារ។

### ឆ. សកម្មភាពរបស់គ្រួសារដែលមានតូបកាត់សក់ ឬអ៊ុតសក់ និងអាជីវកម្មផ្សេងទៀត




ក្រាហ្វិក៤៨ បង្ហាញពីសកម្មភាពអាជីវកម្មគ្រួសារដែលមានតូបកាត់សក់ ឬអ៊ុតសក់ និងអាជីវកម្មផ្សេងទៀត៖ **ខេត្តក្រចេះ** មានចំនួន ៩៨០ គ្រួសារ **ខេត្តមណ្ឌលគិរី** មានចំនួន ៦៥៤ គ្រួសារ **ខេត្តព្រះវិហារ** មានចំនួន ៨៤២ គ្រួសារ **ខេត្តរតនៈគិរី** មានចំនួន ១.៨៤២ គ្រួសារ និង**ខេត្តស្ទឹងត្រែង** មានចំនួន ៨៧៥ គ្រួសារ ។

